ហួត សេងគៀ



# ៤ ឆ្នាំ

រឿងរ៉ាវមួយចំនួនដែលយើងគួរធ្វើ
នៅក្នុងសាកលវិទ្យាល័យ

ហួត សេងគៀ

# ៤ ឆ្នាំ

រឿងរ៉ាវមួយចំនួនដែលយើងគួរធ្វើ
នៅក្នុងសាកលវិទ្យាល័យ

# មាតិកា

ទំព័រដើម ១

ទំព័រថ្លែងអំណរគុណ ៣

ពាក្យណែនាំថ្ងៃដំបូង ៥

រឿងដែលត្រូវធ្វើ ៧

១ ផ្ដោតលើជំនាញ ៩

២ បង្កើតក្រុម ១៣

៣ រៀនស្គាល់ពីគ្រូ ១៧

៤ លេងទឹកមុខ ២១

៥ អានឱ្យបានច្រើន ២៣

៦ សរសេរឱ្យបានច្រើន ២៦

៧ ប្រើអ៊ីនធឺណេតឱ្យអស់ថ្លៃ ២៩

៨ រកការងារធ្វើ ៣៣

៩ ជួយធ្វើការសាលា ៤០

១០ រៀនពីគំនិតច្នៃប្រឌិត ៤២

១១ ស្វែងយល់ពីការបង្កើតអាជីវកម្ម ៤៧

១២ ធ្វើរឿងដែលខុសពីអ្នកដទៃ ៥៤

១៣ សម្រេចក្តីស្រមៃពីមុន ៦០

១៤ ស្រវ៉ាចាប់ភាសាបរទេស ៦៥

១៥ ប្រយ័ត្នអំនួតខ្លួនឯង ៦៧

ទំព័រចុងក្រោយ ៧៧

# ទំព័រដើម

នៅសល់មិនដល់មួយខែទៀតទេ ខ្ញុំនឹងបានសញ្ញាប័ត្រមួយមកទុកនៅផ្ទះហើយ។ ខ្ញុំចាំមកដល់ថ្ងៃនេះ យូរមកហើយ។ ទោះបីជាខ្ញុំមិនសូវចូលចិត្តការរៀននៅក្នុងថ្នាក់ពិតមែន តែមិនបានន័យថា ខ្ញុំមិនដឹងរឿងអ្វីសោះនៅក្នុងសាលានោះទេ។

ខ្ញុំសរសេរសៀវភៅមួយក្បាលនេះឡើង សម្រាប់អ្នកដែលរៀនទើបតែចូលរៀនសាកលវិទ្យាល័យ ហើយមិនដឹងថាគួរធ្វើអ្វីខ្លះ និងមិនគួរធ្វើអ្វីខ្លះ។ សៀវភៅនេះ មិនមែនជាអាថិកំបាំងនោះទេ គ្រាន់តែជាអ្វីដែលខ្ញុំធ្លាប់ធ្វើ កាលដែលខ្ញុំនៅរៀនប៉ុណ្ណោះ។

ខ្ញុំមិនសូវជាមានសំណាង ព្រោះកាលដែលខ្ញុំចូលរៀនដំបូងនោះ មិនមានអ្នកណាមកប្រាប់ខ្ញុំពីរឿងនៅក្នុងសាកលវិទ្យាល័យទេ។ ខ្ញុំជាមនុស្សទីមួយក្នុងគ្រួសាររបស់ខ្ញុំ ដែលអាចរៀនដល់សាកលវិទ្យាល័យ ហេតុនេះ ខ្ញុំមិនបានទទួលការណែនាំអ្វីច្រើននោះទេ។ ម៉ាក់ខ្ញុំគ្រាន់តែប្រាប់ឱ្យទៅសាលារៀននឹងគេ តែប៉ុណ្ណឹងឯង។

៤ឆ្នាំ ក្នុងសាកលវិទ្យាល័យ ទោះមិនច្រើនឆ្នាំពិតមែន តែបើយើងចំណាយខុសដោយមិនបានធ្វើអ្វីសោះនោះ ៤ឆ្នាំនេះ នឹងធ្វើឱ្យយើងស្តាយក្រោយរហូត។ ខ្ញុំក៏មានការស្តាយក្រោយមួយចំនួនដែរ ក្នុង

ពេល៤ឆ្នាំនេះ។ យើងត្រូវចាំថា “ រឿងដែលច្រើនតែធ្វើឱ្យមនុស្ស យើងស្តាយក្រោយ មិនមែនជារឿងដែលយើងបានធ្វើទេ តែជា រឿងដែលយើងមិនបានធ្វើទៅវិញ ” ។

សៀវភៅមួយក្បាលនេះនឹងប្រាប់អ្នកអានទាំងអស់គ្នា ថាអ្វីទៅជា ជីវិតក្នុងសាកលវិទ្យាល័យ និងអ្វីខ្លះជារឿងចាំបាច់។ អ្នកដែលមិន បានរៀនបន្តក្នុងសាកលវិទ្យាល័យ ក៏អាចយកអ្វីដែលមានក្នុងនេះ ទៅប្រើបានដែរ។

ជាចុងក្រោយ ខ្ញុំសូមអរគុណអ្នកដែលបានអានសៀវភៅរបស់ខ្ញុំទាំង អស់ផងដែរ។ ការអានរបស់អ្នកទាំងអស់គ្នា ជាការផ្តល់ឱកាសឱ្យខ្ញុំ បានសរសេរសៀវភៅថ្មីៗបន្ថែមទៀត។ ទោះបីជាសៀវភៅនេះ Free ពិតមែន តែវាក៏មានតម្លៃជាសៀវភៅមួយក្បាលនឹងគេដែរ ដូច្នេះសូមអានដោយយកចិត្តទុកដាក់ផង។ សូមជូនពរឱ្យអ្នកអាន សៀវភៅនេះទាំងអស់ ទទួលបានជោគជ័យក្នុងរយៈពេល៤ឆ្នាំនេះ ចុះ។

ហួត សេងគៀ

ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៥

# ទំព័រថ្លែងអំណរគុណ

ជាដំបូងបង្អស់ ខ្ញុំត្រូវអរគុណដល់សាកលវិទ្យាល័យកម្ពុជា ដែលបានបង្កើតកម្មវិធីប្រកួតប្រជែងសំណេរដើម្បីយកអាហារូបករណ៍ ទើបខ្ញុំអាចជាប់ឈ្មោះចូលរៀននឹងគេ។ ការបានចូលរៀនក្នុងសាកលវិទ្យាល័យនេះហើយ ដែលធ្វើឱ្យខ្ញុំដឹងរឿងកាន់តែច្រើនឡើង។ បន្ទាប់មក គឺអរគុណដល់អ្នកផ្ទះខ្ញុំ ដែលបានជួយជ្រោមជ្រែងខ្ញុំតាំងពីដើមមក រហូតដល់ខ្ញុំរៀនចប់៤ឆ្នាំនេះ។ នេះជាគុណដ៏ធំដែលមិនអាចភ្លេចបាន។

ជាចុងក្រោយ និងសំខាន់ជាងគេនោះ គឺអ្នកដែលបានចូលរួមជួយកែសម្រួលសៀវភៅមួយក្បាលនេះ។ ខាងក្រោមនេះជាឈ្មោះរបស់ពួកគាត់។ ដោយសារអ្នកកែម្នាក់មិនបានប្រាប់ឈ្មោះពិត ហេតុនេះខ្ញុំត្រូវប្រើឈ្មោះក្នុងហ្វេសប៊ុករបស់គាត់ជំនួសវិញ។

- ម៉ូវ យូផេង
- Piano Fde (<u>ឈ្មោះក្នុងហ្វេសប៊ុក</u>)
- កែវ ភួងសង្ហា
- ឡុង សក្កណ្ណាន់
- វី សុខម្ហូ
- ចាន់ ចរិយា

ការជួយរបស់ពួកគេ បានបញ្ជាក់ថា ពួកគេខ្វល់ពីប្រយោជន៍របស់សៀវភៅ ទោះបីជាសៀវភៅនោះ ល្អ ឬមិនល្អក៏ដោយ។ ការជួយមនុស្សដែលមិនធ្លាប់ស្គាល់គ្នា ជារឿងល្អមួយ ព្រោះនេះមិនមែនធ្វើដើម្បីប្រយោជន៍ផ្ទាល់ខ្លួនទេ តែគឺដើម្បីប្រយោជន៍រួម។ ខ្ញុំ ជាអ្នកសរសេរ ពួកគាត់ ជាអ្នកកែ អ្នកដំទៃ ជាអ្នកអាន។ ប្រយោជន៍រួមមានលក្ខណៈបែបនេះឯង។

# ពាក្យណែនាំថ្ងៃដំបូង

មុននឹងចូលរៀន ខាងសាលាបានហៅ និស្សិតឆ្នាំថ្មីទាំងអស់ មកជួបជុំគ្នាដើម្បីស្ដាប់ថ្នាក់ដឹកនាំនិយាយពីរបីម៉ាត់។ កាលនោះ ខ្ញុំអង្គុយកៅអីមុខគេ។ ខ្ញុំស្ដាប់បានទាំងអស់ រាល់អ្វីដែលសាកលវិទ្យាធិការរបស់ខ្ញុំបាននិយាយ។ ទោះបីជាគាត់មកដល់យឺតម៉ោងមែន តែពាក្យដែលគាត់បាននិយាយ មានតម្លៃរហូតដល់ខ្ញុំត្រូវភ្លេចភាពធុញទ្រាន់ក្នុងការអង្គុយចាំគាត់អស់រលីង។

គាត់បាននិយាយថា “ **ពិភពលោកបែងចែកចេញជា ២ គឺ ពិភពក្នុងសាលា និងពិភពនៃការពិត។** ” ពាក្យណែនាំនេះ បានប្រាប់ខ្ញុំឱ្យត្រៀមខ្លួនចូលទៅក្នុងពិភពក្លែងក្លាយមួយទៀត ក្រោយចេញពីវិទ្យាល័យ។ តាមពិត គាត់បាននិយាយរឿងជាច្រើនទៀត តែខ្ញុំចាំបានតែចំណុចនេះប៉ុណ្ណោះ។

នៅក្នុងសាលា គ្រប់យ៉ាងសម្រេចនៅលើចុងប៊ិចរបស់គ្រូ។ បើគ្រូកែឱ្យធ្លាក់ គឺធ្លាក់ដោយមិនអាចប្រកែកបាន។ ក្នុងជីវិតពិត មានរឿងជាច្រើនដែលមកកំណត់ថា យើងនឹងត្រូវជាប់ ឬធ្លាក់។ ខ្លួនយើង ជាកត្តាសំខាន់បំផុតដែលសម្រេចលើភាពជោគជ័យក្នុងជីវិតរបស់ខ្លួន។ ក្រោយពេលដែលបានចូលរៀន ទើបខ្ញុំដឹងថា គាត់និយាយត្រូវទាំង

អស់។ សាកលវិទ្យាល័យ មិនមែនជាជីវិតពិតនោះទេ។ **ខ្ញុំបានស្គាល់រឿងចាំបាច់ជាច្រើន ហើយក៏បានស្គាល់រឿងមិនចាំបាច់ជាច្រើនដែរ**។

គាត់ប្រហែលជាចង់ប្រាប់និស្សិតថ្មីៗ ឱ្យភ្ញាក់ខ្លួនថា ក្រៅពីខំប្រឹងប្រែងក្នុងសាលាហើយ ត្រូវខំទាំងក្រៅសាលាទៀត ព្រោះនោះទើបហៅថាជីវិត។ ជីវិតក្នុងសាលា គ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ រីឯជីវិតខាងក្រៅ ទើបជាអ្វីដែលយើងត្រូវប្រឈមមុខពិតប្រាកដ។

# រឿងដែលត្រូវធ្វើ

ខ្ញុំមានរឿងមួយចំនួនដែលខ្ញុំ និងមិត្តភក្តិបានធ្វើរួច ដើម្បីចែករំលែកទៅកាន់អ្នកអានទាំងអស់គ្នា។ សូមកុំចាត់ទុកអ្វីដែលមានក្នុងសៀវភៅនេះ ជាការបង្រៀន ឬច្បាប់ដែលបង្ខំឱ្យធ្វើតាមឱ្យសោះ។ អ្នកទាំងអស់គ្នា អាចជ្រើសរើសជឿក៏បាន មិនជឿក៏បាន ព្រោះនេះជាសិទ្ធិបុគ្គល តែគ្រប់យ៉ាងដែលខ្ញុំសរសេរ គឺជាការពិត។

ខ្ញុំនឹងផ្ដើមពី រឿងមួយចំនួនដែលត្រូវធ្វើ ព្រោះថា បើសិនជាធ្វើត្រូវ យើងនឹងមិនខ្ជះខ្ជាយពេលទៅលើរឿងអត់ប្រយោជន៍។ ការខ្ជះខ្ជាយពេលវេលា កើតឡើងដោយសារការមិនបានដឹងជាមុន។ ខ្ញុំធ្លាប់ចំណាយពេលចោលច្រើនណាស់ ហេតុនេះ ខ្ញុំយល់ពីអារម្មណ៍សោកស្ដាយ។

ដោយសារតែ សាលាផ្សេងគ្នា មានរបៀបរបបផ្សេងគ្នា ហេតុនេះ អ្នកដែលសម្រេចចិត្តថាអានបន្ត ត្រូវសម្របខ្លួនទៅតាមគោលការណ៍សាលាដោយឡែកពីគ្នា។ ម្យ៉ាងទៀត ខ្ញុំគិតថា មានជំនាញមួយចំនួនដែលមិនចាំបាច់ធ្វើតាមអ្វីដែលខ្ញុំសរសេរនោះទេ ដូចជាវេជ្ជសាស្ត្រ សំណង់ ធនាគារ និងគណនេយ្យជាដើម។ ជំនាញទាំងនេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ទៅលើមេរៀនក្នុងសាលា។ សូមគិតដោយខ្លួនឯងចំពោះបញ្ហានេះ ហើយយកវាទៅ

ប្រើឱ្យមានប្រយោជន៍បំផុតមកវិញ។ នៅទំព័របន្ទាប់ គឺជាកិច្ចការមួយចំនួន ដែលខ្ញុំមិនអាចភ្លេចបាន ក្នុងពេលរៀន។

# ១

# ផ្តោតលើជំនាញ

យើងនឹងលឺគ្រូគ្រប់មុខវិជ្ជា ចូលមកពន្យល់យើងថា មុខវិជ្ជាដែលគាត់បង្រៀនសំខាន់ប៉ុណ្ណោះ។ គ្រូណាក៏និយាយបែបនោះដែរ ព្រោះបើវាមិនសំខាន់ សាលាក៏មិនជួលគាត់មកបង្រៀនដែរ។ ប៉ុន្តែ យើងត្រូវសួរថា តើវាសំខាន់សម្រាប់យើងដែរទេ?

នៅពេលយើងជ្រើសរើសថារៀនអ្វីរួចហើយ យើងត្រូវតែចាប់ជំនាញមួយឱ្យបាន។ កុំខ្វល់ពីរឿងផ្សេងទៀត ធ្វើយ៉ាងណាក៏ដោយត្រូវតែចេះអ្វីមួយឱ្យច្បាស់។ ការរៀនត្រឹមតែមួយដឹង មិនអាចជួយអ្វីយើងបានទេ។

**ពេលវេលាដែលល្អបំផុតក្នុងការរៀនចាប់យកជំនាញ គឺឆ្នាំទីមួយ**។ យើងត្រូវសម្រុករៀនអ្វីដែលសំខាន់ សម្រាប់ជំនាញដែលយើងរើសតាំងពីបើកឆាកទៅឱ្យហើយ បើមិនអញ្ចឹងទេ ប្រាកដជាយឺតពេល។ កាលដែលខ្ញុំរៀនឆ្នាំទីមួយ ខ្ញុំមិនបានដឹងរឿងនេះទេ។ ខ្ញុំរវល់តែខ្វល់ជាមួយនឹងមុខវិជ្ជាដែលគ្រូប្រាប់ថាសំខាន់ ហើយភ្លេចថាខ្លួនឯងក៏មានមុខវិជ្ជាសំខាន់ដែរ។ មានពេលខ្លះ ខ្ញុំចំណាយពេលពីរសប្តាហ៍

ពេញ ដើម្បីចម្លងអ្វីដែលគេសរសេរហើយពីក្នុងសៀវភៅពុម្ព ទៅក្នុងក្រដាសកិច្ចការ ដើម្បីបំពេញចិត្តគ្រូ យកពិន្ទុរួចខ្លួន។ ខ្ញុំបានខាតពេលច្រើនណាស់។

ទម្រាំតែខ្ញុំដឹងថា ខ្ញុំត្រូវរៀនយកជំនាញ គឺឆ្នាំទី៣បាត់ទៅហើយ។ ខ្ញុំរើសយកផ្នែកក្រាហ្វិចឌីហ្សាញ ដែលសាលាខ្ញុំមិនបានផ្តោតសោះ។ ខ្ញុំត្រូវរៀនខ្លួនឯងផង ទៅរៀនតាមមជ្ឈមណ្ឌលផ្សេងៗផង ទម្រាំតែបានការងារធ្វើផ្នែកនេះ។ បើខ្ញុំចេះច្រើនជាងនេះ ប្រហែលជាងាយជាង នៅពេលធ្វើការ។

យើងត្រូវចាំថា ជំនាញ មិនងាយកើតឡើងទេ។ ទោះបីជាយើងមានទេពកោសល្យពីកំណើតមកក៏ដោយ ក៏នៅតែត្រូវការពេលដើម្បីហ្វឹកហាត់ដែរ។ ការស្រាវជ្រាវមួយបានបង្ហាញថា បើសិនជាចង់បង្កើតជំនាញថ្មី យ៉ាងហោចក៏ត្រូវការពេល ៨សប្តាហ៍ដែរ ទើបមើលឃើញលទ្ធផល។**បើយើងមានពេលកាន់តែច្រើន ជំនាញនឹងកាន់តែពូកែ**។ អ្នកទាំងអស់គ្នាធ្លាប់មើលរឿងសាមកុកទេ ? មានឃ្លាមួយគេនិយាយថា "**អ្នកទន់ខ្សោយនឹងត្រូវគេបំភ្លេចចោល**"។ ការគ្មានជំនាញនៅក្នុងខ្លួន នឹងធ្វើឱ្យយើងក្លាយជាអ្នកដែលអ្នកដទៃបំភ្លេចចោលមិនខាន។

**ជំនាញផ្ទាល់ខ្លួន ជាតម្លៃរបស់យើងគ្រប់គ្នា**។ មនុស្សដែលគ្មានជំនាញ គ្មានអ្នកណាគេត្រូវការទេ។ នៅពេលយើងដាក់ពាក្យចូលធ្វើការ

សំណួរដែលគេសួរយើង ប្រាកដជា “តើប្អូនចេះអ្វីខ្លះ?” មិនមែន “តើប្អូនរៀនប៉ុន្មានសាលា?” នោះទេ បើសិនគេមិនសួររកជំនាញរបស់យើង នោះយើងត្រូវត្រៀមខ្លួនធ្វើការតាមបែបវេទនាខ្លួនឱ្យហើយទៅ។ កាលខ្ញុំធ្វើការនៅកាស៊ីណូ គេអត់មានសួរខ្ញុំករឿងជំនាញអ្វីទេ គេគ្រាន់តែសួរថា អាចធ្វើការប្តូរវេនបានអត់ប៉ុណ្ណោះ។ ក្រោយមកទៀត ខ្ញុំត្រូវធ្វើការដូចអ្នកទោស។

ចំពោះរឿងជំនាញនេះ យើងត្រូវរើសឱ្យសមនឹងសមត្ថភាពរបស់យើង និងចិត្តស្រលាញ់ផ្ទាល់ខ្លួន។ ជំនាញ ត្រូវនៅជាមួយយើងយូរឆ្នាំណាស់ ហេតុនេះយើងចាំបាច់ត្រូវតែម៉ត់ចត់បន្តិចពេលរើស។ ជួនកាល យើងអាចនឹងមិនដឹងថា នៅក្នុងលោកនេះ មានជំនាញអ្វីខ្លះ តែយើងអាចសួរអ្នកដែលធ្លាប់ដើរមុនយើង ឬអានការណែនាំនៅលើអ៊ីនធឺណេតបាន។ បើដឹងមិនច្បាស់ទេ រើសក៏មិនត្រូវដែរ។

កាលដែលខ្ញុំរើសរៀនមុខវិជ្ជាអាយធីនេះ ក៏ព្រោះតែបានការណែនាំពីពូរបស់ខ្ញុំដែរ។ គាត់ដឹងខ្លះៗដែរពីបច្ចេកវិទ្យាកុំព្យូទ័រ ហើយគាត់ឃើញខ្ញុំចូលចិត្តលេងហ្គេមកុំព្យូទ័រ ហេតុនេះគាត់ក៏ឱ្យយោបល់ថាគួរតែរៀនអាយធីទៅ។ ខ្ញុំក៏បានគិតដែរ ថាជំនាញហ្នឹងល្អឬអត់។ ក្រោយមក ខ្ញុំក៏សម្រេចចិត្តថារៀនផ្នែកនេះ។

តែមានពេលខ្លះ ការធ្វើតាមយោបល់អ្នកដទៃ ក៏អាចឱ្យយើងរើសជំនាញខុសផងដែរ។ មិត្តភក្តិរបស់ខ្ញុំម្នាក់ បានរើសយកជំនាញ

គណនេយ្យ តាមការណែនាំរបស់អ្នកផ្ទះ ដែលតាមពិតគាត់មានសមត្ថភាពក្នុងផ្នែកអាយធីច្រើនជាង។ ក្រោយមក គាត់ក៏ប្តូរមកផ្នែកអាយធីវិញ ព្រោះទៅមិនរួចក្នុងគណនេយ្យ។ គាត់ត្រូវខាតពេលរៀនមុខវិជ្ជាសងសាលាវិញ ហើយថែមទាំងត្រូវរៀនមូលដ្ឋានគ្រឹះឡើងវិញទៀតផង។

មនុស្សយើងអាចមានជំនាញច្រើនក្នុងខ្លួន។ តែបើយល់ល្អ ការមានជំនាញមិនលើសពីបី គឺប្រសើរបំផុត។ អ្នកខ្លះមានជំនាញផ្នែកទីផ្សារផង និងជំនាញផ្នែកកុំព្យូទ័រទូទៅដែរ។ **សូមកុំច្រលំ ការមានជំនាញច្រើន និងការរៀនច្រើនសាលាឱ្យសោះ**។ រៀនច្រើនសាលាមិនប្រាកដថាធ្វើឱ្យយើងមានជំនាញច្បាស់លាស់នោះទេ។ ជំនាញមិនស្ថិតលើសាលាទេ តែស្ថិតនៅលើការខំប្រឹងរបស់យើង។ រឿងពីរខុសគ្នា ហើយផលវាក៏ខុសគ្នាដែរ។ យើងអាចបង្កើនជំនាញមួយឱ្យឆ្អិនល្អមសិន ចាំចាប់ផ្តើមជំនាញថ្មីមួយទៀត។

នេះជារឿងដែលខ្ញុំស្តាយជាងគេបំផុត។ ខ្ញុំរៀនដោយមិនបានចាប់យកជំនាញពីដំបូង ហេតុនេះធ្វើឱ្យយឺតពេលនៅពេលចេញធ្វើការ។ ពេលធ្វើការ ក្រៅពីត្រូវរវល់នឹងការងារហើយ ខ្ញុំត្រូវពង្រឹងជំនាញរបស់ខ្ញុំក្នុងពេលតែមួយទៀតផង។ **បើចង់ចំណេញពេល និងមិនពិបាកខ្លួន គួរតែអភិវឌ្ឍជំនាញតាំងពីដើមឱ្យហើយ**។

# ២

# បង្កើតក្រុម

វិធីសាស្ត្រមួយដើម្បីងាយរៀនក្នុងសាកលវិទ្យាល័យ គឺ បង្កើតក្រុមតូចមួយ។ ការរៀនបែបនេះ មានផលប្រយោជន៍ច្រើន និងបានផលទៀតផង។ ការធ្វើអ្វីតែម្នាក់ឯង មិនមែនជារឿងអាក្រក់ទេ តែនៅក្នុងការសិក្សា ការធ្វើបែបនេះ ជារឿងខាតបង់មួយ។

នៅពេលខ្ញុំចូលរៀនដំបូង ខ្ញុំគ្មានក្រុមទេ។ ខ្ញុំទៅរៀនម្នាក់ឯង មកផ្ទះវិញក៏ម្នាក់ឯង។ ខ្ញុំគិតខុសថា ហេតុអ្វីចាំបាច់មានក្រុម បើខ្ញុំអាចធ្វើកិច្ចការទាំងនេះបានតែម្នាក់ឯង។ ខ្ញុំគិតបែបនោះ ដោយសារតែពេលនោះទើបតែចូលរៀន ហេតុនេះ ចិត្តធុញទ្រាន់នឹងសាលា មិនទាន់កើតឡើង។ ដល់ពេលរៀនយូរទៅ ខ្ញុំចាប់ផ្តើមមានអារម្មណ៍ថាពិបាករៀន ហើយអផ្សុកទៀត។

ក្រោយមក ខ្ញុំបានប្រមូលគ្នាប្រាំនាក់ ដើម្បីរៀនជុំគ្នា។ ពួកយើងរៀនមុខវិជ្ជាអាយធីដូចគ្នាទាំងអស់។ រាល់ពេលមានកិច្ចការផ្ទះ ឬ Assignment ពួកយើងតែងធ្វើជុំគ្នា។ បើសិនជាមានចំណុចណាដែលខ្ញុំមិនយល់ ខ្ញុំអាចសួរអ្នកនៅក្នុងក្រុមបាន ព្រោះកម្រិតខួរ

ក្បាលរបស់ខ្ញុំស្ថិតនៅចំណុចមធ្យមក្នុងក្រុម។ ជួនកាល ការរៀនពីមិត្តភក្តិ អាចនឹងឆាប់យល់ជាងគ្រូបង្រៀនទៀតផង ព្រោះមិត្តភក្តិយើងអាចនឹងយល់ពីយើងបានល្អជាគ្រូ។

ក្រុមរបស់ខ្ញុំ តែងតែធ្វើអ្វីជុំគ្នាជានិច្ច ដូចជា ការសួរគ្រូ ឬសុំអ្វីមួយពីសាលា ហេតុនេះ វាមានភាពងាយស្រួលច្រើន។ សម្លេងភាគច្រើនជាចំណុចសំខាន់នៃជោគជ័យក្នុងសាលា។ ឧបមាថា ពេលខ្ញុំឡើងឆ្លើយសំណួរ ទោះត្រូវឬខុស យ៉ាងហោចណាស់ក៏មានអ្នកនៅក្នុងក្រុមទះដៃឱ្យដែរ។

លើសពីនេះទៀត ខ្ញុំអាចលួចខ្ជិលក្នុងពេលរៀនបានទៀតផង ព្រោះខ្ញុំដឹងថា អ្នកផ្សេងទៀត កំពុងតែមើលគ្រូពន្យល់យ៉ាងយកចិត្តទុកដាក់។ នេះជាអ្វីដែលខ្ញុំចូលចិត្តជាងគេ ក្នុងការរៀនជាក្រុម ព្រោះខ្ញុំឧស្សាហ៍ដេកលក់នៅក្នុងថ្នាក់ណាស់។

ការបង្កើតក្រុម មិនមែនជារឿងងាយប៉ុន្មានទេ ព្រោះវាជាការយកមនុស្សដែលមានចរិតខុសគ្នា មកធ្វើការរួមគ្នា ដើម្បីសម្រេចបានអ្វីមួយ។ ទោះបីវាគ្រាន់តែជាក្រុមដើម្បីរៀនពិតមែន ក៏នៅតែមានបញ្ហាដែរ។ **បញ្ហាធំ គឺអ្នកនៅក្រុមមិនត្រូវគ្នាតែម្តង**។ ដំណោះស្រាយនៅតែមានជានិច្ច បើយើងចង់រកវា។ ដោយសារក្រុមរបស់ខ្ញុំមានគ្នាតិច ហេតុនេះរាល់បញ្ហាមិនសូវជាពិបាកដោះស្រាយប៉ុន្មានទេ។

ខ្ញុំប្រើវិធីងាយៗ ដើម្បីឱ្យក្រុមមួយនេះអាចនៅដំណើរការបានរហូតដល់រៀនចប់ឆ្នាំ។ ដំបូង ខ្ញុំរួមគ្នាដាក់ឈ្មោះក្រុមមួយ ដើម្បីកុំឱ្យភ្លេចថាពួកយើងមានក្រុម។ ពួកយើងសម្រេចយកឈ្មោះ i5Guys ព្រោះយើងមានគ្នាប្រាំនាក់។ កាលនោះដោយសារតែ iPhone កំពុងតែល្បី ហេតុនេះខ្ញុំក៏ខ្ចីអក្សរ i នេះមកប្រើជាឈ្មោះក្រុមសិនទៅ។ ក្រោយមកទៀត ខ្ញុំក៏បបួលពួកគេ បោះពុម្ពអាវយឺតពាក់រួមគ្នាដើម្បីពង្រឹងទំនាក់ទំនងថ្មីនេះ។ ពួកគេក៏យល់ព្រម។ ខ្ញុំក៏ធ្វើ Logo មួយ ដើម្បីដាក់ពីលើអាវ។ ការពាក់អាវដូចគ្នា ជាដំណាក់កាលដំបូងនៃការបង្កើតក្រុមរបស់ខ្ញុំ។

ដោយសារតែពួកយើងមានពេលរៀនជុំគ្នាច្រើនក្នុងឆ្នាំទីមួយ ហេតុនេះ ពួកយើងឆាប់ស្គាល់ចិត្តគ្នាណាស់។ អ្វីដែលខ្ញុំគិត បានដើររហូតដល់ចុងបញ្ចប់នៃការសិក្សាសាកលវិទ្យាល័យដែរ។ ក្រុមនេះនៅតែមាន ទោះបីជាអ្នកនៅក្នុងក្រុមរវល់រៀងខ្លួនក៏ដោយ។

**អ្វីដែលខ្ញុំបានរៀននៅក្នុងក្រុម គឺភាពស្មើគ្នា**។ ខ្ញុំជឿថា **មនុស្សមានភាពពូកែរៀងខ្លួនទាំងអស់** ហេតុនេះ គ្មានអ្នកណាលើសអ្នកណាទេ។ យើងធ្វើការក្នុងក្រុមជាមួយគ្នា ត្រូវចេះគោរពការគិត និងតម្លៃរបស់គ្នាទៅវិញទៅមក។ ការអួតអាង ឬយកមុខមាត់ សុទ្ធតែជាទង្វើរបំផ្លាញមិត្តភាពក្នុងក្រុមទាំងអស់។ នៅមានចំណុចសំខាន់មួយទៀតដែរ គឺការចេះទ្រាំ។ បើយើងមិនចេះទ្រាំខ្លះទេ យើងមិនអាច

ចុះសម្រុងជាមួយអ្នកណាឡើយ។ ខ្ញុំទ្រាំច្រើនរឿងណាស់ ពេលធ្វើការក្នុងក្រុម ហើយអ្នកផ្សេងទៀតក៏ដូចគ្នាដែរ។

ខ្ញុំមានយោបល់មួយ ចំពោះការរើសមនុស្សចូលក្រុម។ យើងមិនគួររើសតែមនុស្សដែលរៀនពូកែមួយមុខមកធ្វើការក្នុងក្រុមនោះទេ។ ការធ្វើបែបនេះ នឹងធ្វើឱ្យក្រុមទៅជាកន្លែងដណ្ដើមមុខមាត់រៀងខ្លួន ហើយមានការប្រកែកគ្នាមិនខាន។ យើងគួររើសអ្នកដែលរៀនមិនចេះខ្លះ អ្នកមិនចង់រៀនខ្លះ ដើម្បីមានភាពរីករាយក្នុងក្រុម។ **ក្រុមដែលគ្មានភាពរីករាយ មិនអាចទទួលបានជោគជ័យ**។

ការរៀនជាក្រុមនៅសាលា អាចធ្វើឱ្យមនុស្សដែលមិនចូលចិត្តសាលា រៀនបានចប់ចុងចប់ដើម។ មិត្តភាពក្នុងក្រុម នឹងបន្តទៅថ្ងៃក្រោយទៀត ដែលវាខុសប្លែកពីការស្គាល់គ្នាត្រឹមតែអង្គុយរៀនជាមួយគ្នាធម្មតា។ មនុស្សជាច្រើនក្រោយពេលរៀនចប់ ធ្វើជាមិនស្គាល់នៅពេលជួបគ្នាខាងក្រៅសាលា។

# ៣

# រៀនស្គាល់ពីគ្រូ

តើអ្នកណាជាអ្នកកំណត់ថាយើងនឹងជោគជ័យ ឬបរាជ័យ ក្នុងការសិក្សា? គឺគ្រូ។ ហេតុនេះ ការស្វែងយល់ពីគ្រូ ជារឿងសំខាន់។

ដោយសារតែគ្រូ ក៏ជាមនុស្ស ដូច្នេះ ពួកគាត់មានចរិតខុសប្លែកគ្នាតាមធម្មជាតិ។ គ្រូខ្លះ តឹងរឹងពេលបង្រៀន ប៉ុន្តែធូរពេលឱ្យពិន្ទុ។ គ្រូខ្លះ ចូលចិត្តលេងសើច តែម៉ត់ចត់ពេលពន្យល់មេរៀន។ គ្រូខ្លះទៀត មានចិត្តលំអៀងទៅលើតែសិស្សណាដែលចេះអែបអបគាត់ប៉ុណ្ណោះ។ មានគ្រូច្រើនប្រភេទណាស់ដែលយើងនឹងត្រូវជួប។

ចំពោះគ្រូដែលស្រួលនិយាយគ្នាជាមួយសិស្ស មិនមានអ្វីពិបាកទេ។ ប៉ុន្តែ វាមិនមែនបែបនេះរហូតទេ។ ខ្ញុំធ្លាប់រៀនជាមួយគ្រូម្នាក់ ដែលចូលចិត្តនិយាយអួត។ គាត់និយាយពីសញ្ញាប័ត្រ ពីស្នាដៃរបស់គាត់ ហើយនិយាយពីគ្រួសារគាត់។ ពេលខ្លះ ខ្ញុំច្រឡំស្មានថាគាត់មកឃោសនារកសំឡេងឆ្នោតក្នុងថ្នាក់ទៀតផង។ គាត់មានចិត្តលំអៀងចំពោះសិស្ស។ មានសិស្សជាច្រើន និយាយដើមគាត់ក្រោយខ្នង។ ខ្ញុំក៏បាននិយាយខ្លះដែរ ព្រោះខ្ញុំចង់ចូលរួមចែករំលែកបទពិសោធន៍

អាក្រក់ជាមួយគេ។ យើងត្រូវចាំថា **គ្មានសិស្សណាអាចនិយាយដើមគ្រូទេ បើគ្រូមិនមានដើមរឿងឱ្យនិយាយមុន**។

ម៉ាក់ខ្ញុំជាគ្រូថ្នាក់បឋមម្នាក់។ គាត់តែងតែប្រាប់ខ្ញុំថា "**ទៅរៀន កុំចង់ឈ្នះគ្រូ ព្រោះវាគ្មានបានការអីទេ**"។ ការណែនាំមានប្រយោជន៍ណាស់ ជាពិសេសនៅក្នុងសាកលវិទ្យាល័យ។

នៅពេលដែលយើងព្យាយាមយកចាញ់ឈ្នះជាមួយគ្រូ បើមើលមួយភ្លែត យើងហាក់ដូចជាក្លាហាន និងគួរឱ្យមានមោទនភាពណាស់ តែបើមើលយូរទៅ យើងដូចជាមិនដឹងអ្វីសោះតែម្តង។ **គ្រូមិនមែនជាអ្នកដែលយើងត្រូវគិតយកចាញ់ឈ្នះទេ ហើយសាលារៀន ក៏មិនមែនជាកន្លែងដណ្តើមយកមុខមាត់គ្នាដែរ**។ វាមិនខុសពីអ្វីដែលសាកលវិទ្យាធិការរបស់ខ្ញុំនិយាយតាំងពីដំបូងទេថា សាលារៀន ជាពិភពក្លែងក្លាយ។

គ្រូបង្រៀនអាយធីនៅសាលាខ្ញុំម្នាក់ ក៏បាននិយាយប្រាប់ដែរថា "**ឈ្នះគ្រូបានប្រយោជន៍អី បានតែធ្លាក់ហ្នឹង**"។ គាត់និយាយបែបលេងសើចមែន តែនេះជាការពិត។ គ្រូ មិនមែនជាព្រះទេ បើធ្វើមិនសមរម្យជាមួយគាត់ និទ្ទេស F នឹងក្លាយជាអំណោយដ៏ថ្លៃថ្លាពីគាត់មិនខាន។ យើងមករៀនជាមួយគាត់ ដើម្បីរកចំណេះដឹង មិនមែនចង់រករឿងដាក់ខ្លួននោះទេ។

ខ្ញុំមិនដែលប្រកែកជាមួយគ្រូណាម្នាក់ទេ ព្រោះខ្ញុំជឿអ្វីដែលម៉ាក់ខ្ញុំនិយាយ។ រាល់លើកពេលដែលខ្ញុំប្រឡងមិនចេះ ហើយមិនដឹងសរសេរអ្វីនៅក្នុងក្រដាស ខ្ញុំតែងតែសរសេរសុំពិន្ទុគ្រូជានិច្ច។ ខ្ញុំមិនមែនចេះតែសរសេរសុំគ្រប់គ្រូនោះទេ ព្រោះគ្រូខ្លះក៏តឹងជ្រុលពេក។ វិធីនេះ ខ្ញុំប្រើតាំងពីចូលរៀនដំបូងម្ល៉េះ ហើយបានផលច្រើនណាស់។ ពេលខ្លះ ចម្លើយដែលត្រូវឆ្លើយនោះ មានច្រើនចំណុចពេក ហួសពីសមត្ថភាពចងចាំរបស់ខ្ញុំ ដូច្នេះ ខ្ញុំត្រូវសរសេរប្រាប់គ្រូតាមត្រង់ថាខ្ញុំបានមើលមេរៀនហើយ តែភ្លេចប៉ុន្មានចំណុចនេះ។ គាត់ក៏អនុគ្រោះឱ្យខ្ញុំ។ នេះជាគ្រាន់តែជាវិធីដោះទាល់ប៉ុណ្ណោះ សូមកុំយកវាមកធ្វើជាលេសក្នុងពេលប្រឡងឱ្យសោះ។ មេរៀនត្រូវតែមើលឱ្យយល់ ឬចាំ តែបើទាល់ច្រកហើយ ចាំប្រើវិធីនេះ។

អ្នកទាំងអស់គ្នាប្រហែលជាគិតថា សាលាដែលខ្ញុំបង្រៀន ប្រហែលជាមានវិន័យមិនតឹងរឹងទេ ទើបសិស្សអាចសុំពិន្ទុពីគ្រូបានបែបនេះ។ សាលាដែលខ្ញុំរៀនមានវិន័យតឹង តែនេះមិនមែនជាហេតុផលដែលធ្វើឱ្យគ្រូបង្រៀនលែងមានការយោគយល់ចំពោះសិស្សនោះទេ។ នៅក្នុងសាកលវិទ្យាល័យ ខុសពីការរៀនថ្នាក់បឋម ឬវិទ្យាល័យ។ និស្សិតអាចនឹងរវល់ក្នុងការងារ ឬបញ្ហាគ្រួសារ ហេតុនេះការលើកលែងត្រូវមាន។ កូនក្មេងមិនចាំបាច់គិតអ្វីទេ ដល់ម៉ោងទៅរៀនមកផ្ទះដេកមើលទូរទស្សន៍ តែមនុស្សធំមិនមែនស្រួលបែបនេះទេ។ រាល់ល្ងាច ខ្ញុំត្រូវជិះម៉ូតូពីកន្លែងធ្វើការឱ្យលឿនបំផុត ដើម្បីទៅដល់

សាលា ហើយបានឆ្លៀតបាយល្ងាចឱ្យហើយ។ និស្សិតខ្លះទៀត មានអ្នកឈឺក្នុងគ្រួសារ ហេតុនេះត្រូវចំណាយពេលច្រើនក្នុងការមើលថែ។ គ្រូបង្រៀនភាគច្រើន សុទ្ធតែដឹងថា និស្សិតដែលមករៀនម្នាក់ៗ សុទ្ធតែមានគោលបំណងផ្សេងគ្នាទាំងអស់ មិនមែននិស្សិតគ្រប់គ្នាមករៀនដើម្បីបានពិន្ទុខ្ពស់រហូតនោះទេ។

ទុកថាខ្ញុំសំណាងចុះដែលបានរៀននៅសាលានេះ ព្រោះថាគ្រូដែលបង្រៀននៅទីនេះស្ទើរតែទាំងអស់ យល់ពីបញ្ហាទាំងនេះ។ ខ្ញុំធ្លាប់លឺអ្នករៀននៅសាលាផ្សេងនិយាយថា ពេលប្រឡងម្តងៗ ពិបាកខ្លាំងណាស់។

សរុបឱ្យខ្លីមកវិញ យើងត្រូវរៀនស្គាល់ពីចិត្តគ្រូឱ្យច្បាស់ និងកុំប្រឹងយកឈ្នះគ្រូ។ ភាពជោគជ័យ ស្ថិតក្នុងដៃរបស់យើង។ បើយើងនៅតែមិនយល់ទៀត ថាឫសគល់នៃភាពជោគជ័យក្នុងសាលាចេញមកពីណា នោះយើងសមនឹងទទួលផលកម្មរបស់យើងហើយ។ តើយើងចង់ឃើញលទ្ធផលប្រឡងចេញមក មានតែឈ្មោះយើងម្នាក់ដែលធ្លាក់ដែរទេ? បើមិនចង់ សូមចងចាំចំណុចទី៣នេះទុក។

# ៤

# លេចទឹកមុខ

មានពាក្យមួយឃ្លាដែលខ្ញុំធ្លាប់អានបានសរសេរថា “**ទឹកមុខអាចបង្ហាញពីទឹកចិត្ត**”។ គ្រាន់តែសង្កេតតាមរយៈទឹកមុខ គេនឹងអាចដឹងថា អ្នកនោះមានអារម្មណ៍បែបណាមិនខាន។ ទឹកមុខស្រស់ស្រាយបង្ហាញថាអារម្មណ៍ស្រស់ស្រាយ។ ទឹកមុខក្រៀមក្រោះ បង្ហាញថាអារម្មណ៍មិនសូវល្អ។

នៅក្នុងសាលា យើងក៏ត្រូវចេះប្រើទឹកមុខ ដើម្បីបង្ហាញពីការយកចិត្តទុកដាក់ ការគោរព និងការប្រឹងប្រែងរបស់យើងដែរ។ ខ្ញុំចូលចិត្តប្រើទឹកមុខណាស់នៅក្នុងសាលា ជាពិសេសជាមួយគ្រូតែម្តង។ ទោះបីជាធុញបែបណាក៏ដោយ ក៏យើងត្រូវចេះរៀនសម្តែងថាពេញចិត្តនឹងមេរៀនដែរ។ មិនមែនទាល់តែជាតួកុនទើបចេះសំដែងបានទេ យើងក៏អាចរៀនបានដែរ។

ភាគច្រើន ខ្ញុំប្រើទឹកមុខនៅពេលប្រឡងប៉ុណ្ណោះ ព្រោះនោះជាពេលសំខាន់សម្រាប់ខ្ញុំ។ ទោះបីជាចេះ ឬមិនចេះក៏ដោយ ខ្ញុំនៅតែប្រើទឹកមុខមួយដដែល គឺ ធ្វើមិនចេះ។ ពេលខ្លះ ខ្ញុំជ្រួញចិញ្ចើមធ្វើដូចជា

កំពុងតែគិតមិនចេញ។ ខ្ញុំឈ្ងោកមុខសរសេរទាល់តែចប់ ទើបខ្ញុំងើបមុខឡើងមើលម៉ោង។ ខ្ញុំសុខចិត្តបើកក្រដាសទៅវិញទៅមក ដើម្បីកុំឱ្យគ្រូគិតថា ខ្ញុំធ្វើហើយលឿនពេក។

ការធ្វើបែបនេះ នឹងនាំឱ្យគ្រូគិតថា យើងយកចិត្តទុកដាក់ធ្វើសំនួរដោយមិនមើលងាយ ឬមានអំនួតជ្រុលពេក។ បើសិនជាយើងចេះប្រើទឹកមុខបែបនេះ ទោះបីជាពិន្ទុដែលទទួលបានមក ល្អ ឬមិនល្អ ក៏មិនមែនបញ្ហាអ្វីដែរ។ វាគ្រាន់បើជាងអ្នកដែលធ្វើឬកគ្រាន់បើហើយប្រឡងបានពិន្ទុទាប។

ម្យ៉ាងទៀត នៅក្នុងបន្ទប់ប្រឡង ក៏មានអ្នកដែលគេមិនចេះដែរ ដូច្នេះការលេងទឹកមុខភ្លើរបស់យើងនេះ នឹងអាចជួយឱ្យអ្នកទាំងនោះ ធូរចិត្តខ្លះដែរ ព្រោះពួកគេនឹងគិតថា មិនមែនមានតែពួកគេទេ ដែលមិនចេះ។ ស្តាប់មើលទៅ ដូចជាមិនសមហេតុផល តែវាជាការគោរពម្យ៉ាងសម្រាប់អ្នកនៅជុំវិញខ្លួន។

ទឹកមុខ សំខាន់ណាស់ មិនថាតែក្នុងសាលា ឬក្រៅនោះទេ ព្រោះវាអាចបង្ហាញពីការគោរព ការដាក់ខ្លួន និងភាពឆ្លាតវៃរបស់យើង។ ការគ្រប់គ្រងទឹកមុខបាន នឹងជួយមិនឱ្យបញ្ហាកើតឡើងមកលើខ្លួនយើង។ សាកល្បងធ្វើសិន ទើបដឹងពីប្រសិទ្ធិភាព។ ពេលដែលយើងរៀនចេះប្រើទឹកមុខហើយនោះ យើងនឹងក្លាយជាមនុស្សថ្មីម្នាក់ទៀតមិនខាន។

# ៥

# អានឱ្យបានច្រើន

តើយើងនឹងបានទទួលចំណេះដឹងតាមណា បើយើងមិនបានអានអ្វីសោះនោះ? យើងត្រូវតែអានឱ្យបានច្រើនក្នុងសាកលវិទ្យាល័យ។ សៀវភៅ ជាវត្ថុទីមួយដែលយើងត្រូវអាន។

នៅក្នុងសៀវភៅ **ប្រយោជន៍ខាងក្នុង** ខ្ញុំបានរៀបរាប់ពីផលប្រយោជន៍ទាំង ៣០ នៃការអានសៀវភៅ។ ហេតុនេះបើសិនជាមានពេលទំនេរ សូមចំណាយពេលអានសៀវភៅនេះបន្ថែម។ យើងត្រូវបើកចិត្តឱ្យទូលាយ ជានិច្ចនៅពេលអាន។

ការអាន ជាកាតព្វកិច្ចរបស់និស្សិត។ កាលខ្ញុំរៀនម៉ោង Database គ្រូដែលមកបង្រៀន បានបង្គាប់ឱ្យសិស្សគ្រប់គ្នាអានសៀវភៅម្ដងមួយចំណុចៗនៅក្នុងថ្នាក់។ គាត់ថា **"មកពីពួកយើងមិនចេះអានទើបរៀនមិនចេះ"**។ ពីដំបូង ខ្ញុំគិតថា គាត់ជាគ្រូខ្ជិល ទើបប្រើឱ្យសិស្សអានជំនួសគាត់ តែក្រោយមកទើបខ្ញុំយល់ពីគោលបំណងរបស់គាត់។ វិធីដែលគាត់ប្រើនេះ បានផលជាងការមើល Slide ដែលរៀបចំទុកទៅទៀត ព្រោះ នៅពេលអាន យើងបានយកចិត្តទុកដាក់

លើគ្រប់ពាក្យទាំងអស់។ ខ្ញុំយល់បានច្រើនជាង ព្រោះក្នុងសៀវភៅមានការពន្យល់លម្អិត និងឧទាហរណ៍ច្បាស់លាស់។

ចុះបើមិនអាន? ខ្ញុំធ្លាប់មានបទពិសោធន៍ហើយ ដែលមិនបានអានមេរៀន គឺប្រឡងធ្លាក់។ ខ្ញុំគ្មានអ្វីសរសេរសោះតែម្តង ព្រោះថាគ្រូចេញសំណួរពីក្នុងសៀវភៅសុទ្ធសាធ។ កាលនោះ ខ្ញុំធ្វើការពេលយប់ ហើយត្រូវងើបមករៀនពេលព្រឹក ដូច្នេះខ្ញុំរៀនមិនចូលសោះ ដល់ពេលប្រឡង ខ្ញុំនៅតែមើលមេរៀនមិនចូលទៀត។ ខ្ញុំគិតថាប្រហែលជាគ្រូចេញសំនួរបើកទេ ព្រោះមុខវិជ្ជាដែលខ្ញុំរៀននោះ គឺសង្គមវិទ្យា។ តែ ការប្រហែលរបស់ខ្ញុំនេះ ធ្វើឱ្យខ្ញុំត្រូវបង់លុយរៀនមុខវិជ្ជានេះឡើងវិញ។ គ្រប់យ៉ាងដែលចេញមានក្នុងសៀវភៅទាំងអស់ តែស៊ុយត្រង់ថា វាមិនមាននៅក្នុងខួរក្បាលខ្ញុំសោះនៅពេលប្រឡង។ ធ្លាក់តែម្តង ខ្ញុំចាំរហូត។

ក្រៅពីសៀវភៅ យើងក៏អាចអានតាមអ៊ីនធឺណេតបានដែរ។ ឥលូវនេះ ពួកយើងចំណាយពេលច្រើនជាងមុននៅលើអ៊ីនធឺណេត ហេតុនេះ សូមកុំឱ្យពេលវេលាទាំងនោះខាតបង់ទៅ ដោយមិនបានទទួលអ្វីមកវិញឱ្យសោះ។

ប្រធានបទដែលយើងអាន គួរតែធំទូលាយបន្តិច ព្រោះដើម្បីស្គាល់ពីរឿងនៅជុំវិញខ្លួនឱ្យបានច្រើន។ ក្រៅពីពតិមាន យើងត្រូវអានឯកសារផ្សេងទៀតដែលអាចនឹងមានប្រយោជន៍ដល់អ្វីដែលយើង

កំពុងរៀន។ **ពួកយើងរៀនមកដល់សាកលវិទ្យាល័យហើយ មិននៅក្មេងដូចមុនទេ ហេតុនេះ ចំណេះដឹងដែលយើងមាន ក៏គួរតែរីកធំធាត់ដូចរាងកាយយើងដែរ**។

ទោះបីជាមួយថ្ងៃ អាចអានបានត្រឹមតែ១០ ឬ ២០ នាទី ក៏ចាត់ទុកជារឿងល្អដែរ ឱ្យតែធ្វើបានជាប់លាប់។ ការអាន ជាទម្លាប់ល្អមួយដែលគ្រប់គ្នាត្រូវតែមាន។ កុំចាំតែគេបង្ខំយើងឱ្យអាន ត្រូវចេះអានដោយខ្លួនឯង។

# ៦

# សរសេរឱ្យបានច្រើន

ដៃគូរបស់ការអាន គឺការសរសេរ។ នៅក្នុងពេលរៀន ការសរសេរដើរតួនាទីសំខាន់ណាស់ ជាពិសេសពេលប្រឡង។ មានគ្រូបង្រៀនម្នាក់បានប្រាប់ពីមូលហេតុ ដែលគាត់តែងតែដាក់សំណួរច្រើននៅពេលប្រឡងថា “ គាត់ចង់ឱ្យសិស្សហ្វឹកហាត់ការសរសេរឱ្យបានច្រើន ”។ គាត់គិតត្រូវហើយ ព្រោះមានតែពេលប្រឡងទេ ទើបសិស្សគ្រប់គ្នា ខំប្រឹងសរសេរ ក្រៅពេលនេះ គ្មានអ្នកណារវល់នឹងការសរសេរឡើយ។

ការសរសេរ ក៏ជាការហ្វឹកហាត់ខួរក្បាលមួយបែបដែរ។ វាធ្វើឱ្យយើងគិតបានលឿនជាងអ្នកដទៃ ព្រមទាំងមានហេតុផលសមរម្យទៀតផង។

ការសរសេរ ទាមទារឱ្យយើងអានបានច្រើន ដើម្បីហាត់រៀនពីរបៀបសរសេរពីអ្នកដទៃ ហើយកែច្នៃវាមកជារបស់ខ្លួនឯង។ ការសរសេរ ក៏ទាមទារពេលវេលាច្រើនផងដែរ ក្នុងការហ្វឹកហាត់។ សំណេរដំបូងៗ នឹងធ្វើឱ្យយើងមានអារម្មណ៍ថា គ្មានសមត្ថភាព តែ

នោះគ្រាន់តែជាការសាកល្បងប៉ុណ្ណោះ។ ការហ្វឹកហាត់ជាប្រចាំ នឹងធ្វើឱ្យសំណេររបស់យើងមានការវិវឌ្ឍទៅរកចំណុចល្អ។ យើងមិនចាំបាច់យកស្នាដៃរបស់យើងទៅប្រៀបនឹងអ្នកនិពន្ធអាជីពនោះទេ ព្រោះការធ្វើបែបនេះ ជាការមើលងាយខ្លួនឯងប៉ុណ្ណោះ។

នៅក្នុងសាលា គេប្រើសំណេរមួយបែបហៅថា Academic Writing គឺជាការសរសេរដោយប្រើក្បួនខ្នាតត្រឹមត្រូវដដែលៗគ្រប់ពេល។ បើសិនជាយើងមិនអាចសរសេរតាមទម្រង់នេះបាន ក៏មិនបញ្ជាក់ថា យើងខ្សោយ ឬមិនបានការដែរ។ យើងអាចងាកមកសាកល្បងសរសេរបែប Creative Writing ដែលជាការសរសេរដោយប្រើបែបផែនផ្ទាល់ខ្លួន ធ្វើយ៉ាងណាឱ្យអ្នកអានយល់បានងាយ និងជក់ចិត្ត។

ខ្ញុំមានបញ្ហា ជាមួយ Academic Writing ហេតុនេះរាល់ពេលប្រឡង ខ្ញុំប្រើ Creative Writing មកជំនួសរាល់លើក។ ពេលគ្រូដាក់សំណួរឱ្យពន្យល់ ខ្ញុំច្រើនតែនិយាយរឿងអ្វីមួយប្រាប់ទៅគាត់វិញ ព្រោះថាបើមិនធ្វើបែបនេះទេ ខ្ញុំប្រាកដជាហុចក្រដាសសឱ្យគ្រូមិនខាន។ ពិន្ទុខ្ញុំមិនសូវល្អប៉ុន្មានទេ តែអាចប្រឡងជាប់នឹងគេដែរ។

ការសរសេរ ក៏ជាមធ្យោបាយដ៏ល្អមួយ សម្រាប់បង្ហាញគំនិតរបស់យើងមកកាន់ខ្លួនឯងដែរ។ ការធ្វើបែបនេះ មានប្រយោជន៍ ព្រោះគ្រប់គ្នាសុទ្ធតែមានគំនិតរៀងខ្លួន តែដើម្បីឱ្យយើងមើលឃើញពី

ភាពច្បាស់លាស់របស់គំនិតដែលយើងមាន យើងចាំបាច់ត្រូវតែ សរសេរវាចេញមកខាងក្រៅ។ Jack Dorsey ស្ថាបនិកម្នាក់របស់ក្រុមហ៊ុន Twitter ធ្លាប់បានបង្ហើបពីវិធីគិតរបស់គាត់ថា គាត់ត្រូវតែសរសេរអ្វីដែលគាត់គិតចេញមកលើក្រដាស ព្រោះវាធ្វើឱ្យគាត់មើលឃើញវាកាន់តែច្បាស់។ យើងក៏អាចប្រើវិធីនេះបានដែរ។

ទោះបីយើងគិតថា យើងមានទេពកោសល្យក្នុងការសរសេរ ឬគ្មានក៏ដោយ យើងគួរតែផ្តល់ឱកាសឱ្យខ្លួនឯងខ្លះ ដើម្បីរៀនសរសេរពីអ្វីដែលយើងចង់បាន។ វាអាចជាការសង្ខេបមេរៀន សំណួរចម្លើយ ឬជាគំនិតដែលលេចឡើងភ្លាមៗ។

សូមកុំទុកឱ្យអ្វីដែលបានកើតឡើង ក្នុងវ័យកំពុងរៀនរបស់យើងបាត់ទៅដោយមិនចងចាំអ្វីសោះ។ យើងគួរតែកត់ត្រាវាទុកខ្លះ ព្រោះយ៉ាងហោចណាស់ ក៏យើងអាចដឹងបានថា យើងបានរៀនអ្វីខ្លះកាលពីមុនដែរ។

# ៧

# ប្រើអ៊ីនធឺណេតឱ្យអស់ថ្លៃ

នៅក្នុងសម័យដែលបច្ចេកវិទ្យាកំពុងតែរីកចម្រើនបែបនេះ ការចេះប្រើអ៊ីនធឺណេត នឹងជួយសំរួលការងារក្នុងសាលារបស់យើង។ ចំណេះដឹងថ្មីៗទាក់ទងនឹងអ្វីដែលយើងកំពុងរៀន ត្រូវបានគេបញ្ចូលទៅក្នុងប្រព័ន្ធអ៊ីនធឺណេត ដូច្នេះ យើងមិនគួររំលងនោះទេ។

ក្នុងប្រទេសយើង នៅពេលដែលនិយាយពីការប្រើអ៊ីនធឺណេត គេនឹងនឹកឃើញដល់ ហ្វេសប៊ុក ឬ Youtube ភ្លាម តែវាគ្រាន់តែជាផ្នែកមួយនៃអ៊ីនធឺណេតប៉ុណ្ណោះ។ ក្រៅពីបង្ហោះរូប និងមើលវីដេអូ យើងអាចធ្វើអ្វីបានច្រើនជាងនេះទៀត។ យើងអាចអានពត៌មានថ្មីៗពីបរទេស ឬអាចសួរសំណួរនៅក្នុង Forum ទៀតផង។

នៅលើអ៊ីនធឺណេត មានវេបសាយល្បីៗ និងមានប្រយោជន៍ជាច្រើនដែលយើងគួរតែស្គាល់។ កាលខ្ញុំរៀនក្នុងឆ្នាំទី៣ គ្រូបង្រៀនម៉ោង Photoshop ម្នាក់បានបង្ហើបវេបសាយមួយដល់ខ្ញុំ។ ការបង្ហើប

របស់គាត់នេះ បានធ្វើឱ្យខ្ញុំងាកមករៀនផ្នែកឌីហ្សាញរហូតមកដល់ឥឡូវ។ គាត់បានប្រាប់ពី **Pinterest** ដែលជាបណ្ដាញសង្គមមួយដែរ តែវាមិនដូចហ្វេសប៊ុកទេ។ បណ្ដាញសង្គមនេះ ផ្ដោតតែលើរូបភាពប៉ុណ្ណោះ តែវាសម្បូរបែបណាស់។ កាលនោះខ្ញុំរៀន Photoshop ដូច្នេះខ្ញុំលួចគំនិតល្អៗជាច្រើនពីក្នុងនោះ ហើយខ្ញុំក៏បន្តប្រើវាមកទល់នឹងសព្វថ្ងៃ។ ពេលធ្វើការ បើសិនជាខ្ញុំរកនឹកឌីហ្សាញអ្វីមិនឃើញទេ ខ្ញុំនឹងបើកវាមើលមួយសន្ទុះ ដើម្បីប្រមូលគំនិតពីអ្នកដទៃ ហើយយកមកច្នៃតាមរបៀបផ្ទាល់ខ្លួន ។

មាននិស្សិតជាច្រើន ដែលមិនទាន់ទាំងចេះប្រើ Google ផង។ ពួកគេមិនយល់ពីវិធី Search ឱ្យចំ Keyword (គឺជាពាក្យគន្លឹះដែលគេប្រើនៅក្នុងការ Search)។ និស្សិតខ្លះទៀត មិនទាំងដឹងថាត្រូវចូលទៅ Google តាមណាទៀតផង។ ប្អូនខ្ញុំក៏មិនចេះប្រើ Google ពីមុន តែដល់ខ្ញុំប្រាប់ខ្លះ ស្ដីឱ្យខ្លះទៅ ក៏ឃើញចេះរកចម្លើយមេរៀនរបស់វា។ គ្រូអាយធីម្នាក់នៅក្នុងសាលាខ្ញុំតែងនិយាយថា “ **បើមានចម្ងល់ សួរតែ Google ទៅដឹងហើយ** ” ។ ខ្ញុំឯកភាព១០០ភាគរយ ព្រោះខ្ញុំប្រើវារាល់ថ្ងៃ។

ការរៀនដោយប្រើអ៊ីនធឺណេតជាជំនួយ ធ្វើឱ្យយើងទទួលបានចំណេះដឹងថ្មីច្រើន បើប្រៀបនឹងការរៀនតាមសៀវភៅធម្មតា។ យើងដឹងហើយ សៀវភៅពិបាកក្នុងការបោះពុម្ពឡើងវិញណាស់

ហើយរាល់ការផ្លាស់ប្ដូរសៀវភៅ ឬមេរៀនម្ដងៗ ខាងសាលាត្រូវរៀបចំឯកសារទៅដល់ក្រសួងទៀត ដូច្នេះគេមិនសូវប្ដូរសៀវភៅសិក្សាទេ។ ខ្ញុំមិនប្រាកដថា សាលាផ្សេងគេធ្វើបែបនេះឬអត់ទេ តែសាលាខ្ញុំ គឺរៀនសៀវភៅចាស់។ បញ្ហាកើតឡើង តែវាមានដំណោះស្រាយស្រាប់។ ខ្ញុំប្រើអ៊ីនធឺណេតដើម្បីស្វែងរកអ្វីដែលថ្មីទាក់ទងនឹងមេរៀនរបស់ខ្ញុំ។

កាលដែលខ្ញុំរៀនបង្កើតវេបសាយដំបូង គ្រូបានយកមេរៀនចាស់មកបង្រៀន។ ខ្ញុំអាចមើលដឹង ព្រោះនៅលើ Slide មានដាក់ឆ្នាំដែលគេផលិត។ ខ្ញុំក៏ទៅរៀនតាមអ៊ីនធឺណេតវិញ។ ខ្ញុំក៏អាចសរសេរកូដបានដែរ តែមិនស្ទាត់ទេ។ សាកគិតទៅមើល បើខ្ញុំរៀនតែអ្វីដែលគេឈប់ប្រើ តើខ្ញុំនឹងយកមកប្រើការក្នុងបច្ចុប្បន្នដោយរបៀបណាបាន?

ខ្ញុំមានវេបសាយមួយដែលខ្ញុំគិតថាអ្នកគ្រប់គ្នាគួរតែសាកល្បងប្រើ។ វាជា Forum តែមិនរញ៉េរញ៉ៃដូច Forum ដទៃទៀតទេ។ វាឈ្មោះថា Quora ។ នៅក្នុងនោះ យើងអាចសួរសំណួរដែលយើងមិនយល់ទៅកាន់អ្នកដទៃបាន ហើយយើងនឹងភ្ញាក់ផ្អើលនៅពេលបានអានចម្លើយពីពួកគេ។ អ្នកប្រើប្រាស់វេបសាយនេះ ភាគច្រើនជាអ្នកជំនាញ ឬអ្នកដែលមានបទពិសោធន៍ក្នុងផ្នែកណាមួយ។ ពួកគេអាចពន្យល់យើងបានយ៉ាងល្អ។ ខ្ញុំនៅចាំថា សំនួរដំបូងដែលខ្ញុំសួរ

គឺទាក់ទងនឹងការរៀនគូររូប។ បន្ទាប់ពីសួរហើយ ស្អែកឡើងខ្ញុំក៏បានទទួលចម្លើយយ៉ាងច្រើន។ ខ្ញុំក៏បានយកចម្លើយទាំងនោះមកសរសេរឡើងវិញនៅក្នុងប្លុករបស់ខ្ញុំ ព្រោះវាល្អមែនទែនតែម្ដង។ អ្នកដែលមិនធ្លាប់ប្រើ Quora នឹងមិនដឹងពីភាពអស្ចារ្យរបស់វាទេ។ មានពេលខ្លះ ខ្ញុំញៀននឹងវាដូចលេងហ្វេសប៊ុកដែរ។ បើចង់បានចំណេះដឹងថ្មីៗ សូមសាកល្បង Quora។ ខ្ញុំហ៊ានធានាថា អ្នកទាំងអស់គ្នានឹងមិនស្ដាយក្រោយទេ បើសិនជាបានប្រើវា។

សរុបឱ្យខ្លីមកវិញ យើងត្រូវប្រើអ៊ីនធឺណេតឱ្យសមនឹងតម្លៃរបស់វា ព្រោះយើងត្រូវចំណាយលុយគ្រប់វិនាទីទៅលើវា។ យើងត្រូវស្វែងរកវេបសាយល្អៗមួយចំនួន ហើយប្រើវាឱ្យបានច្រើន។ ហ្វេសប៊ុកក៏ដោយ បើសិនជាចេះប្រើ យើងនឹងទាញបានប្រយោជន៍ជាច្រើនពីវា តែបើមិនចេះប្រើទេ នឹងខាតពេលអត់ប្រយោជន៍មិនខាន។

# ៨

# រកការងារធ្វើ

ក្នុងសង្គមយើងមានមតិ ២ ប្រឆាំងគ្នា។ មតិមួយយល់ថា “នៅពេលកំពុងរៀន និស្សិតមិនគួរធ្វើការទេ គួរតែខំប្រឹងរៀនឱ្យពូកែ ចាំរៀនចប់ ចាំធ្វើការ”។ ឯមតិមួយទៀតយល់ថា “នៅពេលកំពុងរៀន និស្សិតគួរតែរកការងារធ្វើដើម្បីឱ្យមានបទពិសោធន៍ច្រើន”។ ខ្ញុំមិនហ៊ានថា មតិណាមួយត្រូវ ឬខុសទេ តែដោយសារសៀវភៅនេះសរសេរតាមបទពិសោធន៍ផ្ទាល់ខ្លួន ខ្ញុំគាំទ្រមតិទី ២ ទាំងស្រុង។

**ផលប្រយោជន៍ធំបំផុតនៃការធ្វើការក្នុងពេលរៀន គឺ ទទួលបានបទពិសោធន៍ពិត**។ ការបង្រៀននៅក្នុងសាលា គ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ។ យើងមិនដឹងថា ទ្រឹស្តីណាមួយប្រើបាន ឬមិនបានទេ តែយើងគ្រាន់តែដឹងថា បើវាចេញលើក្រដាសប្រឡង យើងអាចធ្វើបានឬអត់ប៉ុណ្ណោះ។ បទពិសោធន៍នៅក្នុងការងារ ជារបស់មានតម្លៃ ហើយវាធ្វើឱ្យយើងរស់នៅមានតម្លៃដែរ។ ការងារនឹងជួយបង្រៀនមនុស្ស។ ឧបមាថា យើងរៀនចេះបាន ៥ ភាគពីសាលា ដល់ពេលចេញធ្វើការ យើងនឹងចេះថែម ២ ទៅ ៣ ភាគទៀត។

បើសិនជាយើងធ្លាប់ចំណាយពេលខ្លះ ឆែកមើលការប្រកាសរើសបុគ្គលិក យើងនឹងឃើញថាក្រុមហ៊ុនភាគច្រើនរើសយកមនុស្សដែលមានបទពិសោធន៍យ៉ាងហោចណាស់ ក៏មួយឆ្នាំឡើងទៅដែរ។ មិនមែនថាគេមើលរំលងសញ្ញាប័ត្រពីសាលាទេ តែសញ្ញាប័ត្រគ្រាន់តែអាចបញ្ជាក់ថាយើងបានដឹងពីទ្រឹស្តីប៉ុណ្ណោះ វាមិនមែនជាអ្វីដែលគេចង់បានពិតទេ។

និស្សិតខ្លះ ត្អូញត្អែរថា “ទើបតែរៀនចប់ ទៅយកបទពិសោធន៍មកពីណាកើត”។ ចុះអំឡុងពេលរៀនហ្នឹង ម៉េចក៏មិនខំរកការធ្វើឱ្យហើយទៅ? នៅពេលខ្ញុំរៀនឆ្នាំទី ១ ខ្ញុំនឹកឃើញចង់ធ្វើការ។ ខ្ញុំក៏ទៅដាក់ពាក្យនៅកាស៊ីណូធ្វើជាអ្នកគិតលុយ។ វាជាការងារដំបូងរបស់ខ្ញុំ ហេតុនេះបទពិសោធន៍ដែលទទួលបានពេលនោះ គឺថ្មីទាំងអស់។

ខ្ញុំដឹងពីរបៀបពិនិត្យលុយក្លែងក្លាយ និងបិទបញ្ជីតូចៗ។ ខ្ញុំដឹងពីចិត្តអត់ទ្រាំនៃការឈរធ្វើការ។ ខ្ញុំដឹងពីភាពឃ្លាននៅពេលដែលគ្មានអ្នកមកដូរទៅហូបបាយ។ ខ្ញុំដឹងពីការនិយាយដើមគ្នា និងប្រកាន់បក្សពួកក្នុងការងារ។ ខ្ញុំដឹងពីរបៀបការពារខ្លួនពីការរុញកំហុសរបស់អ្នកដទៃ។ ខ្ញុំដឹងពីប្រសិទ្ធិភាពនៃកាម៉េរ៉ាសុវត្ថិភាព។ ខ្ញុំដឹងពីគំនិតរបស់អ្នករួមការងារ។ ជាពិសេស គឺដឹងថា **បទពិសោធន៍ការងារ មានតម្លៃជាងសញ្ញាប័ត្រ**។ ខ្ញុំធ្វើបាន១ ឆ្នាំ ក៏សុំឈប់ទៅ ព្រោះខ្ញុំគិតថាគ្រប់គ្រាន់ហើយ ល្មមដល់ពេលរកកន្លែងថ្មីហើយ។

ក្រៅពីបទពិសោធន៍ យើងនឹងទទួលបានប្រាក់ខែ។ លុយដែលយើងរកបានដោយខ្លួនឯងនេះហើយ ដែលធ្វើឱ្យយើងយល់ច្បាស់ពីជីវិត។ កាលមិនទាន់ចេះរកលុយ យើងមិនដឹងថា លុយបានមកដោយរបៀបណាទេ យើងគ្រាន់តែដឹងថា វានៅជាមួយឪពុកម្តាយយើងប៉ុណ្ណោះ។ តែលុយទាំងនោះ បានពីកម្លាំង និងពេលវេលារបស់ពួកគាត់។ នៅពេលចូលធ្វើការ ខ្ញុំចេះសន្សំលុយ ទិញរបស់ដោយខ្លួនឯង និងចេះចាយវាយត្បិតត្បៀតជាងមុន ព្រោះខ្ញុំដឹងថាលុយពិបាករក។

យើងមិនអាចឃើញអ្នកដទៃចាយលុយធូរ ហើយប្រឹងធ្វើតាមគេបានទេ។ វាអាចមកពីគ្រួសារគេរកលុយធូរដែរ ហេតុនេះលុយមិនមែនជាបញ្ហាចោទសំខាន់របស់គេទេ។ ខ្ញុំតែងងាកមើលមកស្ថានភាពគ្រួសារខ្ញុំគ្រប់ពេល។ ខ្ញុំធ្លាប់សួរម៉ាក់ខ្ញុំថា តើយើងក្រ ឬក៏មាន? តែគាត់ឆ្លើយថា មិនក្រ ហើយក៏មិនមានដែរ។ អញ្ចឹង គឺបានន័យថាក្រហើយ គ្រាន់តែគាត់មិនចង់និយាយឱ្យចំពាក្យ។ ខ្ញុំត្រូវរកការងារធ្វើដោយខ្លួនឯង ដើម្បីបានលុយមកទុកចាយវាយខ្លួនឯង។ ខ្ញុំមិនចង់ជញ្ជក់ឈាមគ្រួសារខ្ញុំយូរពេកទេ។

ខ្ញុំមានយោបល់មួយទាក់ទងនឹងការសន្សំលុយនេះដែរ។ សម្រាប់អ្នកដែលចង់មានមុខជំនួញផ្ទាល់ខ្លួន ការធ្វើការក្នុងពេលរៀនជាឱកាសល្អមួយ។ យើងនឹងអាចមានលុយសម្រាប់ធ្វើអ្វីដែលយើងចង់ធ្វើ ហើយអាចបង្កើតទំនាក់ទំនងជាមួយអ្នកដទៃបានទៀតផង។

បើសិនជា ថៃដន្យ ការងារដែលយើងធ្វើនោះ រីកចម្រើន ហើយផ្ដល់ចំណូលឱ្យយើងបានច្រើន នោះក្រោយពេលរៀនចប់ យើងអាចមានលទ្ធភាពបើកមុខរបរអ្វីមួយដោយខ្លួនឯងយ៉ាងងាយ។ ដើមទុន ទំនាក់ទំនង ឱកាស និងបទពិសោធន៍ ជាគ្រាប់ពូជសំខាន់នៃការធ្វើជំនួញ។ វត្ថុទាំង ៤ នេះ សុទ្ធតែអាចបង្កើតបានទាំងអស់។

សាច់ញាតិខ្ញុំម្នាក់ ធ្លាប់បាននិយាយប្រាប់ខ្ញុំថា "**រៀនផង ធ្វើការផង ទើបយើងឆ្លាត**"។ ដំបូងខ្ញុំគិតថា គាត់ចង់ផ្ដោតលើការរៀនឆ្លាត តែតាមពិត គឺភាពឆ្លាតក្នុងការរស់នៅសោះ។ អ្នកដែលរៀនតែមួយមុខ មិនដែលធ្វើការអ្វីសោះ ប្រៀបដូចជាខ្វះអ្វីម្យ៉ាងនៅពេលនិយាយជាមួយអ្នកដទៃ។ ដោយសារតែមិនដឹងថា ការងារពិតប្រាកដមានលក្ខណៈបែបណា ពួកគេ ក៏និយាយទៅតាមការស្រមៃរបស់ខ្លួន។ ពេលខ្លះ ភ្លាវមែនទែន តែក៏គួរឱ្យចង់សើចដែរ។

បកចូលមករឿងឆ្លាតវិញ តើអ្វីជាភាពឆ្លាតក្នុងការរស់នៅ? **មនុស្សម្នាក់ដែលចាត់ទុកថាឆ្លាត គឺជាមនុស្សដែលចេះសម្របខ្លួននឹងអ្វីដែលនៅជុំវិញ**។ មានតែអ្នកដែលធ្លាប់ធ្វើការទេ ទើបចេះសម្របខ្លួន។ នៅក្នុងថ្នាក់រៀន គ្រប់ពេលដែលយើងចង់បដិសេធ ឬមានយោបល់អ្វីមួយ យើងតែងតែនិយាយភ្លាម ដោយមិនខ្វល់ពីអ្នកដទៃ។ ជួនកាល យើងគិតថា "**ចេះនិយាយតែអញ អ្នកផ្សេងភ្លើទាំងអស់**"។ គំនិតបែបនេះ គេមិនយកទៅប្រើទេនៅកន្លែងធ្វើការ ព្រោះវាធ្វើឱ្យ

គេស្អប់។ នៅពេលធ្វើការ យើងនឹងរៀនចេះបិទមាត់ រៀនលើក យោបល់នៅពេលសមរម្យ រៀនសួរ រៀនធ្វើល្ងង់ រៀនស្តាប់អ្នក ដទៃ និងរៀនពីខ្លួនឯងបានច្រើន។

នៅមានហេតុផលមួយទៀត ដែលយើងត្រូវគិតឱ្យច្បាស់។ ក្រោយ ពេលរៀនចប់ តើយើងសង្ឃឹមប៉ុន្មានភាគរយ ថានឹងអាចរកការងារ ដែលល្អបានធ្វើ? បើសិនជាគ្មានសង្ឃឹមទេ យើងគួរតែរកការងារធ្វើ បណ្តើរៗឱ្យហើយទៅ។ **រៀនមិនទាន់ចប់ មានការងារធ្វើ ប្រសើរ ជាងរៀនចប់ហើយ ដើរទាត់ខ្យល់ដែរ**។ និស្សិតខ្លះ រើសអើងការងារ ដោយគិតថា ខ្លួនគេមានសញ្ញាប័ត្រត្រឹមត្រូវ ហេតុអ្វីត្រូវមកធ្វើការ តូចតាច? ការគិតបែបនេះ ប្រហែលជាត្រឹមត្រូវ។ ដូច្នេះទើបយើង គួរតែធ្វើការនៅពេលកំពុងរៀន ព្រោះពេលនោះយើងមិនទាន់មាន សញ្ញាប័ត្រអ្វីទាំងអស់។ មុខមាត់ក៏មិនសូវបាត់បង់ ហើយចិត្តយើង ក៏មិនរងសម្ពាធដែរ។ ក្រោយពេលរៀនចប់ យើងនឹងមានបទ ពិសោធន៍ស្រាប់ក្នុងដៃ គ្រប់យ៉ាងនឹងកាន់តែងាយស្រួល។

តើយើងនឹងមានអារម្មណ៍បែបណា បើដាក់ពាក្យធ្វើការធ្លាក់គ្រប់ កន្លែងនោះ? ហើយវានឹងកាន់តែមានសម្ពាធថែមទៀត នៅពេល រៀនចប់ តែបែរជារកការងារធ្វើមិនបាន។ សូមកុំភ្លេចថា **យើងរៀន ក៏ដើម្បីតែធ្វើការដែរ មិនមែនរៀនដើម្បីយកឈ្មោះតែជានិស្សិតទេ**។

បើសិនជាអាច ឆ្នាំទី១ ជាឆ្នាំដែលល្អបំផុតសម្រាប់ចាប់ផ្តើមធ្វើការ។

សម្រាប់មធ្យោបាយដើម្បីបានការងារធ្វើមានច្រើនដូចជា ចូលតាមខ្សែ ដាក់ពាក្យតាមអ៊ីនធឺណេត ឬសេវាកម្មស្វែងរកការងារជូននិស្សិត ឬសុំគេចូលតែម្តង។ ក្នុងចំណោមវិធីទាំង ៣ នេះ ការចូលតាមខ្សែងាយស្រួលជាងគេ។ យើងអាចសាកសួរគ្រូ ឬក៏មិត្តភក្តិ ថាតើមានកន្លែងណាដែលយើងអាចធ្វើការបានទេ។ បើគ្រួសារយើងមានមុខមាត់ដែរ ការប្រើខ្សែ រឹតតែគ្មានបញ្ហាហើយ។

ខ្ញុំដឹងថា អ្នកទាំងអស់គ្នានឹងគិតថា ការចូលតាមខ្សែ ជាភាពអយុត្តិធម៌សម្រាប់អ្នកដែលគ្មានខ្សែ តែវាជាការពិត។ យើងត្រូវទទួលស្គាល់វាជាមុនសិន។ ក្រុមហ៊ុនមួយចំនួន រើសបុគ្គលិកតាមរបៀបនេះ គឺ ទាល់តែអ្នកខាងក្នុងអស់ខ្សែដែលអាចអូសចូលបានទើបគេរើសមនុស្សពីក្រៅ។ ការធ្វើបែបនេះក៏មានប្រយោជន៍ដែរ គឺការទុកចិត្តគ្នា និងទំនាក់ទំនង។ ដោយសារសុទ្ធតែជាអ្នកដែលស្គាល់គ្នា ដូច្នេះការធ្វើការងារជាមួយគ្នា វាកាន់តែងាយស្រួលជាងមុន។ បើយើងគិតថាយើងគ្មានខ្សែ នោះបានន័យថា យើងគ្មានទំនាក់ទំនងជាមួយអ្នកណាទាំងអស់ តែដូចជាមិនអញ្ចឹងទេ។

ការរៀន និងការងារ ត្រូវតែដើរទន្ទឹមគ្នា ទើបមានលទ្ធផលល្អ។ យើងអាចនឹងរៀនខ្សោយជាងអ្នកដទៃ តែយើងមានអ្វីដែលអ្នករៀនពូកែមិនមាន។ នោះគឺ បទពិសោធន៍ដែលបានឆ្លងកាត់ដោយផ្ទាល់។ នៅពេលដែលឮគេប្រាប់ថា ការងារ ជាអ្នកបង្រៀនមនុស្ស

សូមជឿគេទៅ ហើយកុំប្រឹងរកហេតុផលមកជំទាស់នឹងការពិតមួយនេះ។ **ការងារមានច្រើនណាស់ ខ្វះតែមនុស្សទៅធ្វើប៉ុណ្ណោះ។**

# ៩

# ជួយធ្វើការឱ្យសាលា

តាមសាលានីមួយៗ មិនខ្វះទេ ការងារឱ្យសិស្សធ្វើ។ ភាគច្រើនជាការងារស្ម័គ្រចិត្ត ឬធ្វើដើម្បីប័ណ្ណបញ្ជាក់អ្វីមួយពីសាលា។ សម្រាប់ខ្ញុំ ការជួយធ្វើការឱ្យសាលា ប្រៀបដូចជាការសងគុណសាលាដែលបានផ្តល់ឱកាសឱ្យខ្ញុំបានចូលរៀនដែរ។ ខ្ញុំជាសិស្សអាហារូបករណ៍ ហេតុនេះ ខ្ញុំមិនអាចភ្លេចថា សាលាបានផ្តល់អ្វីខ្លះមកឱ្យខ្ញុំទេ ទោះបីជាខ្ញុំមិនសូវចូលចិត្តរៀនក៏ដោយ។

ខ្ញុំចាំបានថា កាលដែលគេឃោសនាបោះឆ្នោតឆ្នាំ ២០១៣ លោកតាអាចារ្យអេ នៅវិទ្យុ ABC បាននិយាយថា "**សូមកុំបង្រៀនកូនខ្មែរឱ្យរមិលគុណគេ** "។ ខ្ញុំមិនខ្វល់ថាគាត់និយាយដើម្បីលើកជើងខាងណាទេ តែអ្វីដែលគាត់និយាយ ជារឿងត្រឹមត្រូវ។ **រមិលគុណ** មិនមែនជាពាក្យល្អស្តាប់ទេ។ អ្នកដែលប្រើអ៊ីនធឺណេតជាច្រើន ក៏គេធ្វើបែបនេះដែរ។ ពួកគេរៀនចេះពីអ៊ីនធឺណេត បន្ទាប់មកក៏បន្តចែកចាយអ្វីដែលគេចេះទៅកាន់អ្នកដទៃទៀតតាមអ៊ីនធឺណេវិញ។ នេះក៏ហៅថា ការដឹងគុណដែរ។

ខ្ញុំជឿលើរឿង ដឹងគុណអ្នកដទៃនេះ។ ខ្ញុំធ្លាប់ធ្វើការឱ្យសាលាបាន ពីរដងដែរ។ លើកទីមួយ គឺធ្វើជាអនុរក្សក្នុងពេលប្រឡង។ កាល នោះធ្វើតែមួយថ្ងៃទេ ហើយបានបាយថ្ងៃត្រង់មួយពេលទៀតផង។ ឯលើកទីពីរ គឺធ្វើជាជំនួយការរបស់ព្រឹទ្ធបុរសរងមហាវិទ្យាល័យ អាយធី។ ខ្ញុំធ្វើប្រហែល បី ខែ គ្មានបានលុយមួយរៀលចាយទេ តែ នៅតែមកធ្វើដដែល ព្រោះនេះជាការសងគុណ។

ទោះបីជាយើងមិនរៀនដោយសារអាហារូបករណ៍ក៏ដោយ ក៏សាលា នៅតែមានគុណមកលើយើងដែរ។ សាកគិតបែបនេះវិញ ឧបមាថា យើងមានលុយហើយ តែបើគ្មានអ្នកសង់សាលា តើយើងយកលុយ ហ្នឹងទៅធ្វើយ៉ាងណាទើបបានចូលរៀន? ឧបមាថាបានចូលរៀនចុះ តើសាលាមិនបានខិតខំរកគ្រូមកបង្រៀនយើងទេឬ? ចុះបុគ្គលិក របស់សាលា តើពួកគេបម្រើសេវាកម្មឱ្យអ្នកណា?

យើងចូលចិត្តសាលា ឬមិនចូលចិត្ត មិនសំខាន់ទេ អ្វីដែលសំខាន់ គឺ ត្រូវទទួលស្គាល់គុណការដែលសាលាបានធ្វើមកលើយើង។ ការធ្វើ ការឱ្យសាលា ជាមធ្យោបាយមួយដែលយើងអាចសងគុណសាលា បាន។ កុំជំពាក់គុណគេយូរពេក បើសិនជាមានឱកាសហើយ សងឱ្យ ហើយទៅ។ ពាក្យចុងក្រោយដែលយើងគ្រប់គ្នាត្រូវចាំគឺ **កុំធ្វើជា មនុស្សរមិលគុណ!**

# ១០

# រៀនពីគំនិតច្នៃប្រឌិត

ពិភពលោកឈានមកដល់ចំណុចនេះបាន ក៏ដោយសារតែគំនិតច្នៃប្រឌិតរបស់មនុស្សដែរ។ សំណង់ធំៗ បច្ចេកវិទ្យាទំនើបៗ ទស្សនៈល្អៗ និងការរស់នៅដ៏សម្បូរបែប សុទ្ធតែមានកំណើតចេញពីការច្នៃប្រឌិតទាំងអស់។ ក្នុងពេលរៀនក្នុងសាកលវិទ្យាល័យ យើងចាំបាច់ត្រូវប្រើភាពច្នៃប្រឌិតរបស់យើងឱ្យបានច្រើនបំផុត។ ចុះបើសិនជាអត់មាន? គ្មានបញ្ហាទេ។ ព្រោះគំនិតច្នៃប្រឌិត អាចបណ្តុះបាន។

យើងគ្រប់គ្នា សុទ្ធតែអាចក្លាយជាមនុស្សដែលមានគំនិតច្នៃប្រឌិតទាស់ត្រង់ថា កម្រិតនៃការច្នៃប្រឌិតនោះខុសគ្នា ឬដូចគ្នាយ៉ាងណាគឺអាស្រ័យទៅលើមនុស្សម្នាក់ៗ។ ខ្ញុំមានវិធីសាស្ត្រមួយចំនួនដែលអាចធ្វើឱ្យយើងមានភាពច្នៃប្រឌិតនៅក្នុងខ្លួនបាន។

វិធីសាស្ត្រទាំងនេះ អាចប្រើបានផលទាំងអស់ ឱ្យតែយើងដាក់ចិត្តប្រើ។ តែមុននឹងចាប់ផ្តើមអនុវត្ត យើងចាំបាច់ ត្រូវបោះគំនិតចាស់ៗនៅក្នុងខ្លួនយើងចោលមួយឡែកសិន កុំឱ្យវាមកខ្ទប់ផ្លូវគំនិតថ្មីៗ។ គំនិតច្នៃប្រឌិត ជាការបើកចិត្តឱ្យទូលាយទទួលយកអ្វីថ្មីសម្រាប់ខ្លួន

យើង ហើយមានតែការទទួលយកអ្វីថ្មីៗទេ ទើបជីវិតនេះមានន័យពិតប្រាកដ។

**វិធីសាស្ត្រទី មួយ គឺ សង្កេត។** នៅក្នុងសាលា មានមនុស្សមិនក្រោម ១០០នាក់ទេដែលយើងអាចសង្កេតបាន។ យើងត្រូវចាប់យកចំណុចលម្អិតផ្សេងៗដែលនៅជុំវិញខ្លួន ដូចជា ក្លិន ការនិយាយស្តីរបស់អ្នកដទៃ ទឹកមុខ ការសើច ឬវិធីកត់ត្រារបស់អ្នកដទៃ។ មនុស្សដែលមានភាពច្នៃប្រឌិត ចូលចិត្តមើលអ្នកដទៃ ព្រោះពួកគេអាចមើលឃើញបានច្រើនជាងអ្វីដែលកំពុងកើតឡើងទៅទៀត។ បើយើងអាចសរសេរចេញជារឿងខ្លីមួយបាន នៅពេលមានអ្នកណាម្នាក់ដើរកាត់ដោយសាយភាយក្លិនក្រអូប នោះហើយជាគំនិតច្នៃប្រឌិត។

**វិធីសាស្ត្រទីពីរ គឺ រៀន។** គ្មានអ្នកណាចេះដោយមិនរៀនទេ។ យើងអាចរៀន តាមរយៈការអាន ឬបទពិសោធន៍ផ្ទាល់ខ្លួន។ ការអានជួយយើងឱ្យស្រូបយកចំណេះដឹង ដើម្បីជាជំនួយក្នុងការគិត។ ចំណែកបទពិសោធន៍វិញ ជារឿងអស្ចារ្យ។ នៅពេលយើងគូររូបលើកដំបូង ដៃនឹងញ័រ ហើយគូរមិនស្អាតទេ តែក្រោយពេលហ្វឹកហាត់ដដែលៗ រូបដែលចេញមក នឹងចាប់ផ្តើមស្អាតបន្តិចម្តងៗ។ លទ្ធផលបែបនេះ បានមកពីខួរក្បាលយើងដែលរៀនពីកំហុសលើកដំបូង ហើយបង្កើតដំណោះស្រាយឡើងមក។ បទពិសោធន៍ ជាវត្ថុមានតម្លៃចំពោះគំនិតច្នៃប្រឌិត។

ចំពោះមុខវិជ្ជាដែលត្រូវរៀនវិញ ក៏មានច្រើនដែរ ដូចជា សិល្បៈគ្រប់ប្រភេទ ឱហ្សាញ ឬទស្សនៈផ្សេងៗ។ ខ្ញុំរៀនក្រាហ្វិចឌីហ្សាញដោយការអានសៀវភៅ មេរៀនតាមអ៊ីនធឺណេត និងបទពិសោធន៍នានាពីការងារ។ ឌីហ្សាញ បំប៉ោងខួរក្បាលរបស់យើងឱ្យខ្ពស់រហូតដល់អាចមើលឃើញជ្រុងផ្សេងទៀត។ វាបង្រៀនខ្ញុំបានច្រើនណាស់។ បើសិនជាមានគេសួរខ្ញុំ ខ្ញុំនឹងឆ្លើយថា ខ្ញុំក៏ជាមនុស្សមានគំនិតច្នៃប្រឌិតម្នាក់ដែរ គ្រាន់តែមិនសូវខ្លាំង។

គំនិតច្នៃប្រឌិតនេះ នឹងរីកធំធាត់តាមអ្វីដែលយើងបានរៀន។ ហេតុនេះ ចូរកុំបញ្ឈប់ការរៀនរបស់យើង។ សូមកុំខ្លាចថា ផ្ទុះខួរក្បាលដោយសារតែមានគំនិតច្នៃប្រឌិតច្រើនពេកឱ្យសោះ ព្រោះខ្ញុំមិនធ្លាប់ឃើញព័ត៌មានចម្លែកបែបនេះទេ។ ការចង់ចេះ ចង់ដឹង នឹងធ្វើឱ្យយើងរៀនបានច្រើន។

**វិធីសាស្ត្រទី បី គឺ ស្រមៃ។** ការសង្កេត និងការរៀន អាចផ្តល់ឱ្យយើងនូវការពិត តែការស្រមៃនឹងផ្តល់ឱ្យយើងនូវអ្វីដែលហួសពីការពិតទៅទៀត។ នៅក្នុងសៀវភៅ **ប្រយោជន៍ខាងក្នុង** របស់ខ្ញុំ បានលើកឡើងពីការស្រមៃនៅពេលអានសៀវភៅ។ **ការស្រមៃអាចបង្កើតនូវការពិតបាន**។ ការស្រមៃ នេះហើយដែលធ្វើឱ្យគំនិតច្នៃប្រឌិតរបស់មនុស្សឈានដល់ចំណុចកំពូល។

នៅក្នុងរឿង The Lord of The Rings ដែលដឹកនាំសម្តែងដោយ

លោក Peter Jackson ជាឧទាហរណ៍គម្រូមួយក្នុងការប្រែក្លាយគំនិតច្នៃប្រឌិតឱ្យទៅជាវត្ថុពិត។ ខ្សែភាពយន្តនេះ កើតចេញពីដំណើររឿងរបស់សៀវភៅ Lord of The Rings ដែលនិពន្ធដោយ J.R.R Tolkein។ អ្នកដឹកនាំរឿង ប្រើប្រាស់ការស្រមៃដែលបានមកពីពាក្យពេចន៍នៅក្នុងសៀវភៅបង្កើតបានជាផ្ទៃរឿងដ៏អស្ចារ្យមួយក្នុងប្រវត្តិសាស្ត្រខ្សែភាពយន្ត។ Peter Jackson បានអានសៀវភៅរឿងនេះតាំងពីគាត់អាយុ ១៧ ឆ្នាំម្ល៉េះ ហើយគាត់នៅតែស្រមៃថានឹងបង្កើតរឿងនេះឱ្យចេញជារូបរាងឱ្យទាល់តែបាន។

សាកលវិទ្យាល័យ គឺជាកន្លែងដែលយើងអាចរៀនពីគំនិតច្នៃប្រឌិតបានងាយបំផុត។ បណ្ណាល័យ អ៊ីនធឺណេត និងមនុស្សនៅជុំវិញខ្លួនសុទ្ធតែជាធនធានសម្រាប់បង្កើនភាពច្នៃប្រឌិត។ រាល់ចម្ងល់ដែលយើងមាន ហើយមិនអាចរកចម្លើយបាន យើងអាចសួរគ្រូ ឬអ្នកដែលរៀនមុនយើងបាន។ បទពិសោធន៍របស់ពួកគេ នឹងបង្ហាញផ្លូវយើងកាន់តែច្បាស់។

គំនិតច្នៃប្រឌិត នឹងជួយឱ្យយើងរកឃើញដំណោះស្រាយចំពោះបញ្ហាដែលកើតឡើង។ ទាំងក្នុងសាលា និងក្រៅសាលា យើងនៅតែត្រូវការប្រើវាដដែល ហេតុនេះ រៀនពីវាឱ្យហើយ ក៏មិនខាតដែរ។ ខ្ញុំនឹងសរសេរសៀវភៅមួយក្បាលដែលនិយាយ ពីគំនិតច្នៃប្រឌិតនេះ ព្រោះខ្ញុំចង់អានសៀវភៅបែបនេះជាភាសាខ្មែរយូរហើយ។ ហើយខ្ញុំ

ក៏សង្ឃឹមថានឹងមានអ្នកអានសៀវភៅក្រោយរបស់ខ្ញុំទៀត។

បើសិនជាយើងស្គាល់ និងប្រើប្រាស់គំនិតច្នៃប្រឌិត យើងនឹងមើលឃើញពីភាពខុសប្លែកគ្នាក្នុងការរស់នៅ។ យើងនឹងក្លាយជាមនុស្សដែលគិតក្នុងផ្លូវវិជ្ជមាន និងរីករាយចំពោះអ្វីដែលជួបប្រទះ។ ថាមិនត្រូវ យើងអាចក្លាយជាគម្រូ និងកម្លាំងជំរុញចិត្តដល់អ្នកដទៃទៀតផង។

ខ្ញុំមានចំណុចតូចមួយចង់បញ្ជាក់បន្តិច ដើម្បីកុំឱ្យមានការយល់ខុស។ គំនិតច្នៃប្រឌិត មិនទាក់ទងនឹងភាពឆ្លាតទេ។ វាទាក់ទងនឹងបែបផែននៃការមើលទៅកាន់អ្វីមួយ និង គិតពិចារណា។ មនុស្សល្ងង់ម្នាក់ ក៏អាចមានគំនិតច្នៃប្រឌិតខ្ពស់បានដែរ ហេតុនេះ សូមកុំព្យាយាមអួតខ្លួនឯងថាឆ្លាត នៅពីមុខអ្នកដទៃ។ គំនិតច្នៃប្រឌិត ជាការដោះស្រាយបញ្ហា មិនមែនជាគ្រឿងអលង្ការដើម្បីអួតគ្នាទេ។

# ១១

# ស្វែងយល់ពីការបង្កើតអាជីវកម្ម

ដើម្បីសេរីភាព និងភាពអស្ចារ្យក្នុងជីវិត យើងគួរតែរើសយកការបង្កើតអាជីវកម្មផ្ទាល់ខ្លួន។ មិនថាវាមានទំហំតូចប៉ុណ្ណាទេ ឱ្យតែជាកម្មសិទ្ធិរបស់យើង យើងអាចរស់នៅស្កប់ស្កល់ហើយ។

ការធ្វើអាជីវកម្ម មិនងាយស្រួលដូចអ្វីដែលយើងធ្លាប់ឃើញគេសរសេរនៅលើអ៊ីនធឺណេតនោះទេ។ ការចាប់ផ្ដើមបោះលុយរកស៊ីដោយមិនដឹងទិសខ្យល់ នឹងធ្វើឱ្យយើងខាតបង់ជាមិនខាន ហេតុនេះទើបយើងត្រូវចំណាយពេលដើម្បីរៀនជាមុន។ នៅអំឡុងពេលជានិស្សិត គឺជាឱកាសល្អបំផុតក្នុងការស្វែងយល់ពីអាជីវកម្ម ព្រោះយើងមិនដឹងថា ខ្លួនយើង អាចមានសំណាងក្លាយជាថៅកែឬអត់ទេក្រោយពេលរៀនចប់។

ចំណុចមួយនេះ មិនមែនសម្រាប់អ្នកដែលមានគ្រួសារធូរធារ ឬជាគ្រួសារអ្នករកស៊ីនោះទេ ព្រោះខ្ញុំជឿថា ពួកគាត់ដឹងច្បាស់ជាងខ្ញុំទៅ

ទៀត។ ចំណុចនេះ សរសេរសម្រាប់អ្នកដែលមានស្ថានភាពពិបាក និងមិនមានអ្នកណែនាំពីការធ្វើអាជីវកម្ម។

បើយើងតាមដានឱ្យច្រើនបន្តិច យើងនឹងឃើញថា គ្រូបង្រៀនភាគច្រើននៅតាមសាកលវិទ្យាល័យ មានមុខជំនួញផ្ទាល់ខ្លួនជានិច្ច ដូចគ្រូរបស់ខ្ញុំម្នាក់ គាត់បើកក្រុមហ៊ុនទេសចរណ៍ក្នុងស្រុកមួយ។ គាត់ធ្លាប់បានប្រាប់ពីការស្វែងរកភ្ញៀវ និងវិធីដែលគាត់ផ្សព្វផ្សាយពាណិជ្ជកម្មនៅលើ Google។ គាត់ក៏មានវេបសាយអាយធីផ្ទាល់ខ្លួនមួយដែរ ដែលអាចរកចំណូលឱ្យគាត់បានប្រហែលជា ៣ សន្លឹកក្នុង ១ខែ។ សម្រាប់ខ្ញុំ គឺលើសពីល្មមចាយ ទៀតផង។

បទពិសោធន៍ ដែលគេចែករំលែកដោយមិនគិតលុយបែបនេះ សម្បូរណាស់នៅក្នុងសាលា ជួនកាលអាចជាមនុស្សក្បែរខ្លួនផងក៏ថាបាន។ មិត្តភក្តិខ្ញុំម្នាក់ មានតូបលក់បបរខ្យងក្នុងផ្សារតាខ្មៅ ។ ខ្ញុំក៏ធ្លាប់ទៅមើលផ្ទាល់នឹងភ្នែកដែរ។ តូបនោះ លក់ដាច់មែន។ អ្នកចូលទិញឱ្យណែនកៅអី។ អ្វីដែលធ្វើឱ្យខ្ញុំភ្លឺភ្នែកនោះ គឺប្រាក់ចំណេញពីមុខរបរនេះ។ គ្រាន់តែជាអាជីវកម្មខ្នាតតូចផង ចុះទម្រាំអាជីវកម្មខ្នាតធំទៀត តើសល់ច្រើនប៉ុន្មានទៅ?

ពេលខ្លះ អ្នកដទៃ គេមិនប្រាប់យើងទេ ទាល់តែយើងហ៊ានសួរគេដែរទើបបានដឹងរឿង។ ខ្ញុំចូលចិត្តសួរអ្នកដែលគេធ្លាប់រកស៊ី អាចនិយាយបានថា ខ្ញុំចូលចិត្តអ្នករកស៊ីច្រើនជាងអ្នកធ្វើការ។ មិនមែន

ដោយសារខ្ញុំមើលងាយការងារទេ គ្រាន់តែចូលចិត្តប៉ុណ្ណោះ។

នៅជាប់របងសាកលវិទ្យាល័យខ្ញុំ មានគេរុញរទេះលក់ទឹក មកលក់នៅក្បែរនោះ។ ខ្ញុំជាម៉ូយទិញទឹកនៅទីនោះដែរ។ ថ្ងៃមួយដោយទ្រាំទប់តណ្ហាមិនបាន ក៏ហើបមាត់សួរគាត់ ថាក្នុងមួយថ្ងៃចំណេញបានប៉ុន្មាន។ គាត់និយាយថា បើកាត់មុខក្រោយចោល ចំណេញបាន ពី ៣០ ទៅ ៤០ ម៉ឺនរៀល។ គាត់និយាយហាក់ដូចជា ចំនួននេះតិចណាស់ តែសម្រាប់ខ្ញុំវិញ បើមើលពីក្រៅមិនអីទេ តែក្នុងចិត្តវិញហៀរទឹកមាត់កក្លាក់បាត់ទៅហើយ។

មុខរបររុញរទេះលក់បែបនេះ ជាប្រភេទមុខរបរដែលមិនល្អមើលទេ តែល្អស៊ី។ លុយចូលជាប្រចាំ ព្រោះមនុស្សយើងទោះបីជាដាក់អ្វីចូលទៅហើយ ក៏នៅតែជុះចេញមកវិញទាំងអស់ ហេតុនេះ អ្នកលក់មិនសូវខ្វល់ថាគ្មានអ្នកទិញទេ។ ម្យ៉ាងគាត់ចេះនិយាយរាក់ទាក់ជាមួយអ្នកទិញទៀត រឿងអីគេមិនជួយទិញគាត់?

ក្រៅពីការសាកសួរអ្នកដទៃ យើងក៏អាចស្វែងយល់ពីរឿងនេះបានដោយខ្លួនឯងដែរ។ នៅលើទីផ្សារសៀវភៅស្រុកខ្មែរយើង មិនខ្វះទេសៀវភៅដែលនិយាយពីការធ្វើអាជីវកម្ម។ យើងគ្រាន់តែទិញមកអានទៅ យើងក៏អាចដឹងខ្លះៗដែរ។ ខ្ញុំមានសៀវភៅ ២ក្បាលដែលខ្ញុំគិតថាល្អក្នុងផ្នែកនេះ។ ទីមួយ គឺ Rich Dad Poor Dad របស់លោក Robert Kiyosaki។ សៀវភៅនេះល្អណាស់ សម្រាប់អ្នក

ដែលចង់ស្វែងយល់ពីមូលដ្ឋាននៃការធ្វើអាជីវកម្មគ្រប់ប្រភេទ។ អ្នកនិពន្ធ បានពន្យល់ក្បោះក្បាយពីគន្លឹះនានា តាមការនិយាយរឿងឡើងវិញ ជាពិសេស គឺ សហគ្រិនភាព។ ទីពីរ គឺ សៀវភៅជីវប្រវត្តិស្ទីវចប ។ សៀវភៅនេះ មិននិយាយផ្តោតទៅលើការរកស៊ីជ្រុលពេកទេ តែនិយាយពីការតស៊ូ និងទស្សនៈរបស់ស្ទីវចបក្នុងការរុញក្រុមហ៊ុនឱ្យឈានមុខគេ។ ស្ទីវចប ត្រូវបានគេចាត់ទុកជាសហគ្រិនឆ្នើមម្នាក់ក្នុងពិភពលោក។ យើងអាចអានជាភាសាអង់គ្លេសក៏បាន ជាខ្មែរក៏បាន ព្រោះមានលក់ទាំងអស់នៅស្រុកយើង។

យើងត្រូវចាំរឿងមួយឱ្យជាប់ គឺការអានសៀវភៅ មិនអាចជួយឱ្យយើងក្លាយជាអ្នកជំនួញជោគជ័យបានទេ តែវាគ្រាន់តែជាកត្តាបូករួម ដើម្បីសម្រេចជោគជ័យប៉ុណ្ណោះ។ ការអានសៀវភៅ ជាការរៀន ហេតុនេះ វាអាចត្រូវខ្លះ ហួសសម័យខ្លះ ជារឿងធម្មតាទេ។

ក្រៅពីសៀវភៅ ប្រភពចំណេះដឹងដ៏ធំមួយទៀតគឺ អ៊ីនធឺណេត។ យើងអាចរកបានបទសម្ភាសន៍ និងគន្លឹះនៃការធ្វើអាជីវកម្មជាច្រើនដោយមិនចំណាយពេលយូរ។ យើងចង់អានក៏បាន ចង់មើលជាវីដេអូក៏បាន ឬចង់ស្តាប់ជាសំលេងក៏បាន។ អ៊ីនធឺណេត អាចធ្វើឱ្យយើងដឹងពីវិធីដែលគេរកស៊ីនៅបរទេស។ ជួនកាល យើងអាចនឹងចាប់បានឱកាសណាមួយពីអ្នកទាំងនោះដែរ។ ទោះបីទីផ្សារយើងមិនសូវធំដូចគេមែន តែឱកាស ល្អមិនអាចមើលស្រាលបានទេ។

បើសិនជាគ្រាន់តែរៀនតាមគេ យើងប្រហែលជាមិនយល់នោះទេ។ មានពេលខ្លះយើងគិតថា យើងយល់ហើយ ដឹងហើយ ទាំងខ្លួនយើងមិនដែលប្រឡូកម្តងណាសោះ។ នេះជាការគិតខុស។ សូម្បីតែអ្នកដែលគេប្រឡូកក្នុងការរកស៊ីយូរឆ្នាំ ក៏មានចំណុចដែលគេមិនយល់ដែរ ចុះទម្រាំតែយើងដែលគ្រាន់តែរៀនពីសៀវភៅ ឬពីអ៊ីនធឺណេត ហេតុអ្វីក៏ពូកែជាងគេម្ល៉េះ? នៅពេលស្វែងយល់ពីអាជីវកម្ម សូមកុំទាន់លើកជើង សមត្ថភាពខួរក្បាលខ្លួនឯងខ្លាំងពេក ព្រោះវាអាចធ្វើឱ្យខាតបង់។

បើសិនជាចង់សាកល្បងឱ្យកាន់តែច្បាស់ទៀត ធ្វើតាមវិធីខ្ញុំទៅ។ យើងត្រូវរកក្រុមហ៊ុនណាដែលទើបបើកថ្មី ហើយចូលធ្វើការនៅទីនោះ យើងនឹងបានដឹងហើយ។ បើគិតមកដល់ពេលដែលខ្ញុំកំពុងសរសេរនេះ គឺ មួយឆ្នាំហើយ ដែលខ្ញុំចូលធ្វើការនៅក្រុមហ៊ុននេះ។ ខ្ញុំរៀនបានច្រើនណាស់ ពីការរកស៊ី និងបើកក្រុមហ៊ុន។ ទោះបីជាខាងក្រុមហ៊ុន មិនសូវឱ្យខ្ញុំចូលទៅពាក់ព័ន្ធនឹងរឿងលុយកាក់ក៏ពិតមែន តែខ្ញុំនៅតែរៀនបានច្រើន។

ក្រុមហ៊ុនដែលខ្ញុំកំពុងធ្វើការ ជាក្រុមហ៊ុន E-Commerce ហេតុនេះចំណូលរបស់ក្រុមហ៊ុន គឺត្រូវពឹងទៅលើការលក់ផលិតផល។ ខ្ញុំមានតួនាទីលក់សៀវភៅផង និងធ្វើជាអ្នកឌីហ្សាញផង។ ការលក់ មិនមែនជារឿងងាយស្រួលទេ ជាពិសេសនៅពេលដែលមានអ្នកលក់

កាន់តែច្រើនឡើងនៅលើអ៊ីនធឺណេត។ ការប្រកួតប្រជែងបែបនេះ ជាអ្វីដែលគេមិនសូវសរសេរនៅក្នុងសៀវភៅ ហេតុនេះខ្ញុំត្រូវសាកល្បងដោយវិធីខ្លួនឯងរហូត។ មានខែខ្លះ ចំណូលដែលលក់បាន មិនគ្រប់ប្រាក់ខែបុគ្គលិកផង។ មានពេលខ្លះ ត្រូវពន្យារពេលបើកលុយក៏មានដែរ។ នេះជាបទពិសោធន៍ដែលខ្ញុំទទួលបាន។

សម្រាប់អ្នកដែលមានចិត្តក្លាហាន មានដើមទុនគួរសម ការបើកអាជីវកម្មដោយខ្លួនឯង គឺជារឿងអស្ចារ្យបំផុត។ នៅពេលដែលយើងកំពុងរៀនបែបនេះ វាមានប្រយោជន៍ច្រើន។ យើងអាចសាកសួរយោបល់ពីគ្រូ និងអាចរកអតិថិជននៅក្នុងសាលាតែម្តង។ នៅសហរដ្ឋអាមេរិចវិញ គេលើកទឹកចិត្តឱ្យ សិស្សដែលរៀននៅសាកលវិទ្យាល័យគួរតែសាកល្បងបង្កើតអាជីវកម្ម ឬក្រុមហ៊ុនដោយខ្លួនឯង ព្រោះបើសិនជាបរាជ័យ ពួកគេអាចមានពេលច្រើនដើម្បីងើបធ្វើម្តងទៀត។ ហេតុនេះទើបនៅប្រទេសគេ មានក្រុមហ៊ុនបើកថ្មីច្រើន។ បើក្រុមហ៊ុនរបស់គេដួល គេក៏ទទួលបានបទពិសោធន៍មួយ ហើយសាកល្បងម្តងទៀត។

ការដាក់ខ្លួនធ្វើដោយផ្ទាល់ និងរៀនពីការងារក្នុងអាជីវកម្ម ជារឿងមានប្រយោជន៍ជាងការទៅរៀនយកសញ្ញាប័ត្រផ្នែក Business ឆ្ងាយណាស់។ មេរៀនដែលយើងទទួលបាន ជាមេរៀនពិតប្រាកដ មិនមែនគ្រាន់តែជាទ្រឹស្តី ឬទិន្នន័យហួសដីលេនោះទេ។

ពួកយើងអាចនឹងគិតថា ខ្ញុំកំពុងសរសេរចាកប្រធានហើយ តែមិនមែនទេ។ ការធ្វើអាជីវកម្មដោយខ្លួនឯង និងការចូលរួមធ្វើជាមួយអ្នកដទៃ សុទ្ធតែជាការស្វែងយល់។ យើងធ្វើបណ្ដើរ រៀនបណ្ដើរ ប្រៀបដូចជា ហូបបាយបណ្ដើរ មើលទូរទស្សន៍បណ្ដើរដែរ បាយក៏ចូលពោះ រឿងក៏ចូលភ្នែក។

ទោះបីជាយើងចង់ធ្វើអាជីវកម្មអ្វីក៏ដោយ សូមចាំថា **ចាប់ផ្ដើមពីតូចទៅ ទើបជាការប្រសើរ**។ បើសិនជាខាតបង់ យើងអាចមានផ្លូវដើរបន្តទៀត។ បើសិនជាចំណេញ យើងអាចចាត់ចែងទៅមុខទៀតដោយមិនបាច់ប្រញាប់ពេក។ អាជីវកម្ម ខុសពីការបកចេក ពេលធ្វើទើបដឹងថាពិបាក។

សម្រាប់អ្នកដែលស្រលាញ់ភាពម្ចាស់ការលើខ្លួនឯង ចំណុចនេះ ជាកន្លែងចាប់ផ្ដើម។ ការស្វែងយល់ពីអាជីវកម្ម នឹងជួយឱ្យយើងក្លាយជាអ្នករកស៊ីម្នាក់ដ៏ពូកែ។ ខ្ញុំជឿថា ថ្ងៃក្រោយទៅនឹងមានក្រុមហ៊ុនថ្មីៗជាច្រើនដែលកើតចេញពីដៃនិស្សិតខ្មែរយើង។

# ១២

# ធ្វើរឿងដែលខុសពីអ្នកដទៃ

ការធ្វើតាមគ្នា បានក្លាយទៅជាទំលាប់មួយរបស់សិស្សទូទៅយូរណាស់មកហើយ។ ការធ្វើបែបនេះ បានធ្វើឱ្យមនុស្សភ្លេចគិតថា ខ្លួនឯងមានភាពខុសគ្នាពីអ្នកដទៃ ហើយយល់ខុសពីធម្មជាតិថា មនុស្សទាំងអស់ដូចគ្នា។ អ្នកខ្លះមិនបានយល់ខុសទេ តែមិនព្រមទទួលស្គាល់តែម្តង។ ការដែលយើងគិតថា អ្នកដទៃនឹងចូលចិត្តអ្វីដែលយើងចូលចិត្ត ជារឿងមិនសមហេតុផលសោះ។

មិនថាអ្នកប្រាជ្ញ ឬមនុស្សល្បីណាទេ ពួកគេសុទ្ធតែបានធ្វើរឿងដែលខុសប្លែកពីអ្នកដទៃ។ បើសិនជាពួកគាត់ ធ្វើដូចតែអ្នកដទៃ តើធ្វើម្តេចនឹងទទួលបានការលើកតម្កើងនោះ? តាមពិតទៅ ការធ្វើខុសពីអ្នកដទៃ ជារឿងល្អ តែដោយសារទស្សនៈតគ្នាក្នុងសង្គម ទើបធ្វើឱ្យយើងមើលឃើញថា វាជារឿងមិនល្អទៅវិញ។ សូម្បីតែម៉ាក់ខ្ញុំ ក៏ប្រដៅខ្ញុំដែរថា "**ធ្វើជាមនុស្ស ត្រូវរស់ឱ្យច្រលំនឹងគេ**" តែពាក្យ

ទូន្មាននេះ ពិតជាមានន័យសម្រាប់ខ្ញុំហើយ។

ខ្ញុំធ្លាប់ធ្វើកិច្ចការក្រុមក្នុងម៉ោង ប្រវត្តិសាស្ត្រខ្មែរ ដែលមានសមាជិក ១០នាក់ជាង។ ប្រធានបទសម្រាប់ក្រុមខ្ញុំគឺ គុណសម្បត្តិនៃសម័យសង្គមរាស្ត្រនិយម។ នៅពេលនោះ គេបានប្រមូលលុយដើម្បីទិញរូបគំនូរព្រះបាទជ័យវរ្ម័នទី៧ ធ្វើជាកាដូឱ្យគ្រូដែលបង្រៀនមុខវិជ្ជានោះ។ ខ្ញុំមិនពេញចិត្តនឹងទង្វើរបែបនោះសោះ ព្រោះវាមិនមែនអ្វីពាក់ព័ន្ធនឹង Assignment សោះ។ ខ្ញុំគិតថា នេះជាការចំណាយលុយអត់ប្រយោជន៍ ហើយម្យ៉ាងទៀត វាហាក់ដូចជាធ្វើឡើងដើម្បីតែមុខមាត់ប៉ុណ្ណោះ។

ខ្ញុំយករឿងនេះមកនិយាយ ដើម្បីបង្ហាញថា តាមពិត មនុស្សមិនមានការគិតដូចគ្នាទេ តើមានហេតុផលអ្វីដែលត្រូវធ្វើតាមគ្នានោះ? យើងត្រូវមានភាពក្លាហានធ្វើរឿងដែលខុសពីអ្នកដទៃ តែកុំឱ្យដើរលើផ្លូវខុសបានហើយ។

នៅសាកលវិទ្យាល័យ ក្នុងពេលដែលអ្នកដទៃ ដើរលេងសប្បាយនៅថ្ងៃឈប់សម្រាក យើងអាចប្រើពេលនោះមកអានសៀវភៅ ឬរៀនជំនាញអ្វីថ្មីក៏បាន។ នៅពេលដែលអ្នកដទៃ ប្រឹងយកមុខមាត់ក្នុងសាលា យើងអាចប្រឹងរកមុខមាត់ពិតប្រាកដក្នុងសង្គម ឬអាជីពរបស់យើងក៏បាន។ សេរីភាព នៃការធ្វើអ្វីខុសពីអ្នកដទៃ មិនត្រឹមតែជួយឱ្យយើងរីករាយនឹងខ្លួនឯងទេ ថែមទាំងមិនបង្កឱ្យមានការ

ស្ដាយក្រោយទៀតផង។

ខ្ញុំមានមិត្តភក្ដិម្នាក់ ដែលបានប្ដូរវេនរៀនខុសពីខ្ញុំ។ គេបានចូលរួមជាក្រុមជាមួយនឹងនិស្សិត ៤-៥នាក់ទៀត។ ក្រុមនេះ ចូលចិត្តដើរលេង ស៊ីចាយ ហេតុនេះ វាខុសពីអ្វីដែលមិត្តភក្ដិខ្ញុំត្រូវការ ប៉ុន្តែដោយសារតែមិនចង់ធ្វើខ្លួនឱ្យខុសពីអ្នកដទៃ មិត្តភក្ដិខ្ញុំត្រូវបង្ខំចិត្តធ្វើតាមគេគ្រប់យ៉ាង។ គេសុខចិត្តមករអ៊ូប្រាប់ខ្ញុំពីរឿងចំណាយច្រើនពេក គ្មានពេលនៅផ្ទះ ឬការធុញទ្រាន់ផ្សេងទៀត។ វាជារឿងធម្មតាទេ នៅពេលដែលធ្វើរឿងដែលមិនត្រូវចិត្ត យើងច្បាស់ជាធុញមិនខាន។

ការធ្វើរឿងដែលខុសពីអ្នកដទៃ បានន័យថា ការធ្វើជាខ្លួនឯងពិតប្រាកដ។ **យើងមិនធ្វើអ្វីដើម្បីឱ្យតែបានខុសពីគេនោះទេ តែយើងធ្វើអ្វីដែលយើងគិតថាត្រឹមត្រូវ និងពេញចិត្តធ្វើប៉ុណ្ណោះ**។

នៅពេលដែលយើងហ៊ានធ្វើខុសពីអ្នកដទៃ យើងត្រូវរៀនចេះពីវិធីមួយទៀត គឺធ្វើជាអ្នកគាំទ្ររបស់ខ្លួនឯង។ យើងត្រូវស្រលាញ់រឿងដែលយើងធ្វើ ព្រោះថា បើយើងមិនចេះស្រលាញ់អ្វីដែលយើងធ្វើ អ្នកដទៃក៏មិនអាចមកស្រលាញ់រឿងនោះបានដែរ។ គ្រប់យ៉ាង ត្រូវចាប់ផ្ដើមពីខ្លួនយើងជាមុន។

ខ្ញុំចាប់ផ្ដើមសរសេរប្លុក houtsengkea.me នៅពេលរៀនឆ្នាំទី៣។

ពេលនោះ ខ្ញុំមិនធ្លាប់គិតថា មានអ្នកដែលចង់អានអ្វីដែលខ្ញុំសរសេរនោះទេ ព្រោះប្រធានបទដែលខ្ញុំយកមកសរសេរ គឺទាក់ទងនឹងរឿងសាមកុកតែប៉ុណ្ណោះ។ តែពេលដែលចាប់ផ្តើម Post អត្ថបទនៅលើហ្វេសប៊ុក ទើបខ្ញុំដឹងថា មានអ្នកដែលគេចូលចិត្តអានច្រើនគួរសមដែរ។

ខ្ញុំប្រាប់តាមត្រង់ចុះ នៅពេលដែលចាប់ផ្តើមសរសេរដំបូង គ្មានមិត្តភក្តិណាម្នាក់គាំទ្រខ្ញុំទេ។ គ្មានអ្នកណាគិតថា ប្លុកជារឿងមានប្រយោជន៍ឡើយ។ ដូច្នេះ ខ្ញុំត្រូវធ្វើជាអ្នកគាំទ្ររបស់ខ្លួនឯងមុនគេបង្អស់។ ខ្ញុំសរសេរហើយ អានខ្លួនឯងរាល់ថ្ងៃ។

ការធ្វើអ្វីខុសពីអ្នកដទៃ មានប្រយោជន៍របស់វា។ **វាអាចធ្វើឱ្យយើងលេចធ្លោបានក្នុងចំណោមអ្នកដទៃបាន**។ ឧទាហរណ៍ងាយមួយចុះ នៅក្នុងថ្នាក់ មានសិស្ស ៥0 នាក់ ម្នាក់ៗសុទ្ធតែស្លៀកពាក់ឯកសណ្ឋាននិស្សិត មានតែយើងម្នាក់ដែលស្លៀកពាក់ខោអាវធម្មតា ហេតុនេះ នៅពេលក្រឡេកមើលមួយភ្លែត យើងជាមនុស្សដែលទាក់ភ្នែកមុនគេ។

**ការធ្វើអ្វីដែលខុសពីអ្នកដទៃ បង្ហាញពីសេចក្តីក្លាហានរបស់យើង**។ មនុស្សជាច្រើន ក្លាយជាជនកំសាក ព្រោះតែខ្លាចពាក្យថា “មនុស្សខុសគេ” ទើបមិនហ៊ានធ្វើតាមចិត្តខ្លួនឯង។ ពួកគេបង្ខំខ្លួនឯងរាល់ថ្ងៃធ្វើតាមតែអ្នកដទៃ ដោយមិនឆ្ងល់ថា តើពួកគេនៅខ្វះអ្វីទៀត។

យើងមិនកើតមកដើម្បីធ្វើតាមអ្នកណាម្នាក់នោះទេ តែយើងកើតមកដើម្បីធ្វើតាមខ្លួនឯង។

កាន់តែអាក្រក់ជាងនេះទៀតនោះ គឺការធ្វើតាមគ្នាខុស។ ដឹងថាគេធ្វើខុសហើយ នៅតែធ្វើតាមគេទៀត ព្រោះមិនចង់ឱ្យគេថាឱ្យ។ នៅពេលធ្វើស្លាយ និស្សិតគ្រប់គ្នា ត្រដរបញ្ចូលទិន្នន័យទាំងឡាយដែលគេរកបាន ដាក់ទៅក្នុងស្លាយ។ ពួកគេធ្វើតាមគ្នា ដោយមិនបានគិតថា វាអាក្រក់មើលទេ។ ពួកគេមិនដឹងថា អ្វីដែលពួកគេកំពុងធ្វើនេះ គឺខុសពីគោលការណ៍របស់ឱីហ្សាញទេ។ សូម្បីតែមិត្តភក្តិខ្ញុំក៏ដោយ ម្នាក់ៗដឹងហើយថា ស្លាយ មិនធ្វើឡើងដើម្បីឱ្យគេអានទេ គឺធ្វើដើម្បីទាក់ទាញចំណាប់អារម្មណ៍អ្នកស្តាប់ប៉ុណ្ណោះ តែដោយសារមិនចង់ឱ្យខុសពីក្រុមផ្សេង ក៏នាំគ្នាធ្វើអ្វីដែលអាក្រក់មើលតាមគេទៅ។

នៅក្នុងពេល ៤ ឆ្នាំនេះ ខ្ញុំព្យាយាមធ្វើរឿងដែលខុសពីអ្នកដទៃច្រើនណាស់។ រឿងខ្លះ ក៏មានផលល្អត្រលប់មកវិញ ខ្លះទៀត ក៏មិនបានផល តែអ្វីដែលសំខាន់ គឺខ្ញុំសប្បាយចិត្ត។ ខ្ញុំគិតថា ខ្ញុំបានធ្វើគ្រប់យ៉ាងរួចស្រេចហើយ។ អ្នកណាក៏អាចធ្វើបានដែរ។ កុំកំសាក គ្រាន់តែរឿងប៉ុណ្ណឹងនោះ។ រាល់ព្រឹក យើងត្រូវស្រូបខ្យល់ចូលក្នុងខ្លួនពង្រីកថ្លើមយើងឱ្យធំ ហើយព្យាយាមធ្វើអ្វីដែលយើងពេញចិត្តបំផុត និងបំភ្លេចចោលចំណង់នៃការធ្វើតាមអ្នកដទៃឱ្យអស់។ អ្នក

ដទៃទេគេរស់នៅទៅតាមជីវិតរបស់គេ ចុះយើងទាក់ទងអីនឹងគេដែរ បានជាខំប្រឹងធ្វើតាមគេម្លេះ?

វាមិនមែនជាបញ្ហានោះទេ បើយើងមិនអាចចូលចំណោមគេចុះ។ វាក៏មិនមែនជាបញ្ហាដែរ បើយើងមិនគិតដូចអ្នកដទៃ។ អ្វីដែលជាបញ្ហានោះ គឺ យើងបានក្បត់នឹងខ្លួនឯង ដើម្បីតែអ្នកដទៃ។ និយាយដល់រឿងក្បត់នេះ ខ្ញុំក៏នឹកឃើញពាក្យសំដីរបស់ ឆាវឆាវ ក្នុងរឿងសាមកុកមួយឃ្លាដែរ។ គាត់បាននិយាយប្រាប់ឆិនកុងថាយថា“ **ប្រហែលពីម្សិលមិញឯងមើលខ្ញុំខុស ប៉ុន្តែថ្ងៃនេះ ឯងមើលខ្ញុំខុសទៀតហើយ ប៉ុន្តែខ្ញុំនៅតែជាខ្ញុំដដែល ខ្ញុំមិនដែលខ្លាចគេមើលខ្ញុំខុសទេ** ” ។ ក្រោយពេលស្តាប់ពាក្យនេះហើយ ធ្វើឱ្យខ្ញុំស្រឡះខួរក្បាលតែម្តង។ តួអង្គដែលខ្ញុំពេញចិត្ត បាននិយាយសម្តីដែលធ្វើឱ្យខ្ញុំពេញចិត្តហើយ។

ការធ្វើខុសពីអ្នកដទៃ ជារឿងសប្បាយ ហេតុនេះសូមកុំភ័យខ្លាច។ បើអ្នកចូលចិត្តអ្វី សូមធ្វើតែរឿងនោះទៅ។ ជីវិតរបស់យើងខ្លីណាស់ កុំបង្កើតការស្តាយក្រោយដល់ខ្លួនឯង។ យើងមានសិទ្ធិគ្រប់គ្រាន់ក្នុងការធ្វើជាខ្លួនឯងពិតប្រាកដ។

# ១៣

# សម្រេចក្តីស្រមៃពីមុន

ក្មេងគ្រប់គ្នា សុទ្ធតែមានក្តីស្រមៃផ្ទាល់ខ្លួន។ ការស្រមៃទាំងនោះ បាននៅជាប់ក្នុងចិត្តក្មេងរហូតដល់ពួកគេ បានចូលរៀនចេះដឹង។ បន្ទាប់មកចំណេះដឹង ក៏បានបង្រៀនពួកគេថា អ្វីជាការពិត និងអ្វីជាការស្រមៃ ហើយបានធ្វើឱ្យក្មេងជាច្រើនបោះបង់ក្តីស្រមៃចោល ដើម្បីរត់តាមសង្គម។

នៅពេលដែលយើងចូលមករៀនដល់សាកលវិទ្យាល័យ គឺជាឱកាសល្អបំផុតក្នុងការប្រមូលយកក្តីស្រមៃទាំងប៉ុន្មានមកគិតឡើងវិញ។ មិនត្រឹមតែគិតប៉ុណ្ណោះទេ យើងត្រូវរកវិធីដើម្បីសម្រេចវាឱ្យក្លាយជាការពិតទៀតផង។ អាយុដែលអាចចូលរៀនសាកលវិទ្យាល័យ គឺជាអាយុដែលត្រូវស្វែងរកអ្វីដែលខ្លួនចង់បានពិតប្រាកដ។

ខ្ញុំក៏មានក្តីស្រមៃតាំងពីក្មេងមកដែរ។ កាលនោះ មីងរបស់ខ្ញុំបានសួរខ្ញុំថា “តើធំឡើងចង់ធ្វើអី?” ខ្ញុំមិនសូវច្បាស់ទេ តែខ្ញុំប្រាប់គាត់ថា ខ្ញុំចង់សរសេរសៀវភៅ។ គាត់ក៏សួរខ្ញុំទៀតថា “សរសេរសៀវភៅប្រលោមលោកមែនទេ?” ខ្ញុំប្រាប់គាត់មិនទាន់ច្បាស់ទេ គ្រាន់តែខ្ញុំ

ចង់សរសេរប៉ុណ្ណោះ។ ខ្ញុំត្រូវចាំយូរណាស់ រហូតដល់ឆ្នាំទី១ ទើបខ្ញុំចាប់ផ្ដើមសរសេរសៀវភៅរបស់ខ្លួនឯង។ សៀវភៅទី១ ដែលខ្ញុំសរសេរមានចំណងជើងថា “**គំនិតខ្ញុំ ចរិតខ្ញុំ**”។ ខ្ញុំសរសេរដោយពឹងលើការយល់ឃើញរបស់ខ្ញុំទាំងស្រុង តែដោយសារកាលនោះខ្ញុំនៅក្មេងពេក មិនសូវដឹងអី ហេតុនេះអត្ថន័យនៅក្នុងសៀវភៅនោះអានហើយចង់តែសើច។ ខ្ញុំមិនដែលបញ្ចេញសៀវភៅនោះ ឱ្យអ្នកណាអានទេ ព្រោះខ្ញុំចង់ទុកវាជារបស់ផ្ទាល់ខ្លួនរហូត។

ក្រោយមក ខ្ញុំក៏បានចងក្រងគំនិតជាច្រើនដែលខ្ញុំបានជួបប្រទះជាសៀវភៅមួយក្បាលទៀត មានចំណងជើងថា “**អាល់ប៊ុមគំនិត**” តែដោយសារខ្ជិលពេក សៀវភៅនេះក៏សរសេរឈប់ៗ ទម្រាំសរសេររួច ខ្ញុំចំនាយពេលអស់ជិតបីឆ្នាំ។ មិនយូរប៉ុន្មាន ខ្ញុំក៏ចាប់ផ្ដើមមើលរឿងសាមកុក។ ខ្ញុំចាប់អារម្មណ៍នឹងសាច់រឿង និងដំបូន្មានក្នុងរឿងនេះណាស់។ ខ្ញុំក៏បានចងក្រងពាក្យសំដីនានានៅក្នុងរឿង ហើយយកមកបង្កើតជាសៀវភៅតូចមួយ ហើយដាក់ចំណងជើងថា “**សម្រង់សម្ដីរឿងនគរទាំងបី**”។ នេះជាសៀវភៅទីមួយ ដែលខ្ញុំបានបញ្ចប់ភ្លាមៗ។ ក្ដីស្រមៃកាលពីក្មេងរបស់ខ្ញុំបានសម្រេចហើយ។ ខ្ញុំមានឈ្មោះនៅលើក្របសៀវភៅហើយ។

ទោះបីជាក្ដីស្រមៃរបស់ខ្ញុំបានធ្វើហើយពិតមែន តែវាមិនទាន់ល្អគ្រប់គ្រាន់នោះទេ។ ខ្ញុំនៅតែបន្ដកែសៀវភៅនោះដល់ទៅបីដងទៀត។

ចំនួនអ្នកដែលចូលចិត្តសៀវភៅរបស់ខ្ញុំ មានការកើនឡើង ដែលភាគច្រើន គឺជាអ្នកដែលចូលចិត្តមើលរឿងសាមកុក។ ខ្ញុំក៏មានកម្លាំងចិត្តច្រើនជាងមុន ហើយក៏សរសេរសៀវភៅថ្មីៗឡើងមក។ សៀវភៅ ២ក្បាលចុងក្រោយរបស់ខ្ញុំ មានគេអានច្រើនគួរសមដែរ។ សៀវភៅ "**រៀនតាមឆាវឆាវ**" ដែលខ្ញុំសរសេរមិនទាន់ចប់ស្រួលបួលផង មានការដោនឡូដលើសពី ៧000 ដង។ ខ្ញុំភ្ញាក់ផ្អើលណាស់ពេលនោះ។ ខ្ញុំឆ្ងល់ថាហេតុអ្វីទើបមានគេដោនឡូដសៀវភៅរបស់ខ្ញុំច្រើនដល់ថ្នាក់នេះ? ទាំងអស់នេះកើតឡើងបានដោយសារតែក្ដីស្រមៃរបស់ខ្ញុំទាំងអស់។

ទោះបីជាខ្ញុំមិនមានសៀវភៅបោះពុម្ពលក់ដូចគេមែន តែសៀវភៅដែលខ្ញុំសរសេរមានអ្នកអាន។ នេះជាគោលដៅរបស់អ្នកសរសេរគ្រប់រូប។ ឱ្យតែមានអ្នកអាន មិនថាតិច ឬច្រើនទេ សុទ្ធតែជារឿងល្អទាំងអស់។ ដូចពាក្យមួយឃ្លាដែលគេច្រើនប្រើនៅពេលស្វែងរកទីផ្សារបច្ចេកវិទ្យាថា "**សុខចិត្តមានមនុស្ស ១00នាក់ ស្រលាញ់ផលិតផលយើង ប្រសើរជាងមានមនុស្ស ១000នាក់ ដែលគ្រាន់តែចូលចិត្តដែរ**"។

អ្វីដែលខ្ញុំរៀបរាប់ខាងលើ មិនមែនជាការអួត និងបញ្ចេញថាខ្លួនខ្ញុំអាចសរសេរបានទេ ព្រោះអ្នកណាក៏អាចសរសេរសៀវភៅខ្លួនឯងបានដែរ ឱ្យតែគេពិតជាចង់សរសេរមែន។ វាជាអំណះអំណាងដែល

បញ្ជាក់ថា **អំឡុងពេលជានិស្សិត ជាឱកាសសម្រេចក្តីស្រមៃដែលយើងមានពីមុន។** ពេលយើងនៅតូច យើងអាចស្រមៃបានមែន តែសមត្ថភាពយើងមិនដល់ ហេតុនេះយើងត្រូវរង់ចាំសិន។

នៅក្នុងសាកលវិទ្យាល័យ យើងនឹងទទួលបានទិន្នន័យជាច្រើន ដែលអាចពាក់ព័ន្ធនឹងក្តីស្រមៃរបស់យើង។ យើងអាចនឹងទទួលបានការណែនាំពីអ្នកដែលបានសម្រេចក្តីស្រមៃ ស្រដៀងនឹងយើងក៏មាន។ **គ្រប់យ៉ាងនឹងកើតឡើងនៅពេលដែលយើងបានត្រៀមខ្លួនរួចរាល់។** ម្យ៉ាងទៀត យើងនឹងអាចបែងចែកដាច់រវាង អ្វីដែលអាចទៅរួច និងអ្វីដែលមិនអាចទៅរួច។ មនុស្សមួយចំនួន មិនអាចសម្រេចក្តីស្រមៃបាន ដោយសារតែអ្វីដែលពួកគេចង់បាន ធំហួសហេតុពេក ឬមិនអាចទៅរួចក្នុងពេលបច្ចុប្បន្ន។

អ្នកទាំងអស់គ្នាប្រាកដជាធ្លាប់មើលរឿង **ស៊ុនអ៊ូខុង** មិនខាន ។ យើងឃើញហើយថា សិស្សទាំងបីរបស់លោកគ្រូថាងចេងសុទ្ធតែមានក្តីស្រមៃ ចង់ធ្វើជាព្រះ។ ពួកគេចង់មានជីវិតដែលរួចផុតពីទុក្ខលំបាក ហេតុនេះទើបខំប្រឹងជូនលោកគ្រូថាងចេង ទៅយកគម្ពីរធមិមកស្រោចស្រង់សត្វលោក។ នៅពេលជិតទៅដល់ក្តីស្រមៃ ពួកគេកាន់តែមានកម្លាំងចិត្តជាងមុន ដោយធ្វើដំណើរមិនសម្រាកយូរដូចពីមុនទៀតផង។ នោះជាឥទ្ធិពលនៃក្តីស្រមៃ។

បើសិនជាថៃដន្យអាក្រក់ យើងមិនធ្លាប់មានក្តីស្រមៃពីមុនមកទេ

នេះជាឱកាសល្អហើយក្នុងការបង្កើតក្តីស្រមៃ និងសម្រេចវាភ្លាមៗតែម្តង។ ការដែលយើងមានក្តីស្រមៃ នឹងធ្វើឱ្យយើងដឹងខ្លួនថា ត្រូវធ្វើអ្វី និងមិនខាតពេលវេលា។ ក្តីស្រមៃតូច ឬធំ មិនសំខាន់ទេ សំខាន់គឺ ត្រូវតែមាន។

មិនថាយើងកើតមកមាន ឬក្រទេ ចាំបាច់ត្រូវតែមានក្តីស្រមៃ។ មានតែក្តីស្រមៃទេ ដែលធ្វើឱ្យយើងមានកម្លាំងចិត្តរស់បន្ត និងរស់ដោយមានន័យបំផុត។ យើងមានពេលច្រើននៅសាកលវិទ្យាល័យ ហេតុនេះ កុំទុកពេលនោះចោល យើងត្រូវប្រើវាមកឱ្យសម្រេចក្តីស្រមៃរបស់យើង។

# ១៤

# ស្រវាចាប់ភាសាបរទេស

ភាសា ជាយានចំលងមនុស្ស។ បើមនុស្សមិនចេះភាសា តើធ្វើយ៉ាងណាអាចរស់នៅជាមួយអ្នកដទៃបាន? ការចេះភាសាបរទេសច្រើនអាចជួយឱ្យយើងស្វែងយល់ពីចំណេះដឹង របស់សាសន៍ដទៃបាន ហើយក៏បង្កើតឱកាសក្នុងទីផ្សារការងារផងដែរ។

តាមសាកលវិទ្យាល័យភាគច្រើន គេប្រើភាសាអង់គ្លេសនៅក្នុងការបង្រៀន ហេតុនេះសិស្សមានឱកាសច្រើនក្នុងការរៀន។ យើងអាចនិយាយថា ភាសាអង់គ្លេសងាយរៀនក៏បាន ពិបាកក៏បានដែរ ព្រោះយើងសុទ្ធតែមានវិធីរៀន និងចំណង់ចំណូលចិត្តដូចគ្នា។

ខ្ញុំមានហេតុផលធម្មតាមួយ ក្នុងការរៀនភាសាអង់គ្លេស។ ហេតុផលនោះគឺ "**ដោយសារតែអ្នកណាក៏គេចេះភាសាអង់គ្លេស អញ្ចឹងហើយទើបខ្ញុំមិនអាចធ្វើព្រងើយនឹងវាបាន**"។ នៅចំណុចមុននេះ ខ្ញុំបាននិយាយពីការធ្វើខុសពីអ្នកដទៃ តែសូមកុំយកចំណុចនេះមកប្រើក្នុងការរៀនភាសាឱ្យសោះ។ យើងមិនត្រូវគិតថា "**ដោយសារតែគេចេះគ្រប់គ្នា ទើបយើងមិនចាំបាច់ចេះ**" នោះទេ។ ការធ្វើខុសអ្នក

ដទៃជារឿងល្អ តែបើធ្វើខុសហើយ បែរជាល្ងង់ជាងគេវិញនោះ សុខចិត្តធ្វើតាមគេវិញប្រសើរជាង។ ម៉ាក់ខ្ញុំតែងតែប្រាប់ខ្ញុំថា ឱ្យតែចេះអង់គ្លេស ទោះធ្វើអ្វីមិនកើត ក៏អាចធ្វើជាគ្រូបង្រៀនបានដែរ។

ក្រៅពីភាសាអង់គ្លេសហើយ នៅមានភាសាជាច្រើនទៀត។ បើសិនជាយើងមានពេលទំនេរ គួរតែឆ្លៀតទៅរៀន១ថ្ងៃ ១ម៉ោងនឹងគេទៅ ព្រោះថា ចេះភាសាវាមិនអត់ប្រយោជន៍នោះទេ។ សូមកុំមានគំនិតថា “ **យើងមិនមែនជាសិស្សផ្នែកអក្សរសាស្ត្រអង់គ្លេស ហេតុនេះមិនបាច់រវល់នឹងភាសានេះទេ** ” ព្រោះនេះជាការបិទផ្លូវដើររបស់ខ្លួនឯងហើយ។

# ១៥

# ប្រយ័ត្នអំនួតខ្លួនឯង

សម័យនេះ វាជារឿងធម្មតាទេដែលអ្នកណាក៏មានអំនួតនៅក្នុងខ្លួននោះ តែបញ្ហាស្ថិតនៅត្រង់ថា តើយើងនឹងគ្រប់គ្រងអំនួតរបស់យើងដោយរបៀបណា? ក្នុងឋានៈជានិស្សិតម្នាក់ យើងមិនគួរមានអំនួតលើខ្លួនឯងទេ។

នៅក្នុងថ្នាក់រៀនណាក៏ដោយ ក៏មានសិស្សខ្សោយ និងសិស្សពូកែដែរ ហើយអ្នកដែលរៀនពូកែ តែងតែមានអំនួតលើខ្លួនឯង អាចតិច ឬច្រើន អាស្រ័យទៅលើចរិតរបស់មនុស្ស។ ដើម្បីឱ្យងាយយល់ ខ្ញុំនឹងបែងចែកការអួតជា ពីរប្រភេទដាច់ពីគ្នា។

ប្រភេទទីមួយ គឺ **អួតលេង** អួតដើម្បីឱ្យមិត្តភក្តិសើចសប្បាយ។ យើងដឹងហើយថា បរិយាកាសរីករាយ កើតឡើងពីមនុស្ស។ រាល់ការនិយាយលេងសើច តែងមានជ្រុលខ្លះ ពិតខ្លះ និងមិនពិតខ្លះអញ្ចឹងហើយ។ ការអួតបែបនេះ មិនមែនជាបញ្ហានោះទេ ព្រោះអ្នកនិយាយគេដឹងថាខ្លួនគេមានសមត្ថភាពប៉ុណ្ណារួចស្រេចហើយ។ ចំណែកអ្នកស្ដាប់វិញ ក៏ដឹងពីសមត្ថភាពរបស់អ្នកនិយាយដែរ ហេតុ

នេះគ្រប់យ៉ាង គឺគ្រាន់តែធ្វើឡើងដើម្បីការសប្បាយប៉ុណ្ណោះ។ យើងសាកគិតទៅមើល បើសិនជានិយាយត្រង់ទៅត្រង់មក ដូចក្នុងល្ខោនបាសាក់ តើរកកន្លែងសើចម៉េចនឹងឃើញ?

ជ្រូកប៉ាកជេ ក្នុងរឿងស៊ុនអ៊ូខុង ឆ្នាំ ១៩៩៦ និង ១៩៩៨ ជាតួអង្គមួយដែលមានអំនួតពីការធ្លាប់ធ្វើជាមេទ័ពឋានលើ។ តែអ្នកដែលមើលរឿងនេះ គ្មានអ្នកណាដែលមិនចូលចិត្ត ប៉ាកជេ ទេ ព្រោះគ្រប់គ្នាសើចនឹងការអួតរបស់គេ។ ប៉ាកជេ មានអំនួតមែន តែអាងអ៊ូខុងជួយ នេះបង្ហាញថា អ្វីដែលគេនិយាយ មិនអាចយកជាការទាំងអស់។ គេនិយាយឱ្យតែបានប៉ុណ្ណោះ ខុសពីអំនួតប្រភេទទីពីរ។

ចំណែកមួយប្រភេទទៀតគឺ **អួតយកមែនទែន**។ មនុស្សប្រភេទនេះចង់បានការសរសើរ ការគោរពកោតខ្លាច និងមុខមាត់ណាស់។ អំនួតប្រភេទនេះហើយដែលយើងត្រូវប្រយ័ត្ន។ ជួនកាល យើងមិនដឹងថាខ្លួនឯងមានអំនួតប្រភេទនេះទេ ។ មនុស្សបែបនេះ តែងតែនិយាយពីចំណុចល្អរបស់ខ្លួនឯងគ្រប់ពេល ហើយព្យាយាមបង្អាប់អ្នកដទៃ។ គេយល់ថា ការធ្វើឱ្យអ្នកដទៃកាន់តែទាប នឹងធ្វើឱ្យខ្លួនគេកាន់តែខ្ពស់។ ជាន់ក្បាលអ្នកដទៃ ដើម្បីតម្លើងកំពស់ខ្លួនឯង ជាអ្វីដែលពួកគេចូលចិត្តធ្វើជាងគេ។

យើងច្រើនច្រលំថា “មានមោទនភាពលើខ្លួនឯង” និង “មានអំនួតលើខ្លួនឯង” ជាពាក្យដូចគ្នា។ វាជាពាក្យខ្មែរដូចគ្នា តែមិនមានន័យ

ដូចគ្នាទេ។ មោទនភាព ជាពាក្យវិជ្ជមាន បង្ហាញពីចិត្តស្រលាញ់ និងគោរពដល់អ្វីមួយ។ ចំណែកអំនួត បង្ហាញពីចិត្តមាក់ងាយ និងធ្វេសប្រហែស។ ហេតុអ្វីបានជាធ្វេសប្រហែស ? ព្រោះថាមនុស្សដែលមានអំនួត គិតថា មានតែខ្លួនទេដែលខ្លាំងជាងគេ មិនអាចមានអ្នកណាប្រជែងបានឡើយ ហេតុដូច្នេះមិនបានត្រៀមខ្លួនទុកជាមុន។

អំនួត មានមកកំណើត តែវាមិនមែនរីកធំដោយគ្មានកត្តាអ្វីជួយសោះនោះទេ។ នៅពេលដែលវាកាន់តែធំ មនុស្សនឹងកាន់តែគ្រប់គ្រងវាលែងជាប់ ហើយក៏ក្លាយទៅជាមនុស្សអឿ។ ចុះហេតុអ្វីបានជាមនុស្សមានអំនួតបែបនេះ? តើមានវិធីដោះស្រាយដែរទេ?

ហេតុផលទី១ គឺ មានទ្រព្យច្រើន។ នេះជារឿងធម្មតាទៅហើយនៅក្នុងស្រុកយើង។ អ្នកណាមានលុយច្រើនជាង អឿបានល្អជាងអួតបានឡូយជាងជានិច្ច។ លុយ អាចធ្វើឱ្យមនុស្សកន្ត្រើម្នាក់ ដើរងើយមុខដូចតារាបង្ហាញម៉ូត និងអាចធ្វើឱ្យគេនិយាយស្តីដូចមេកន្ទ្រាញបាន។ អំនួតដែលចេញមកពីទ្រព្យ ច្រើនតែធ្វើឱ្យអ្នកដទៃជ្រេញ តែប្រហែលជាគ្មានអ្នកណាហ៊ាននិយាយចំមុខទេ ព្រោះខ្លាចអំណាចទ្រព្យ។

ខ្ញុំមានដំណោះស្រាយងាយបំផុត គឺធ្វើឱ្យពួកគេក្ររហាមម្តងទៅលែងហ៊ានអួតហើយ។ ខ្ញុំនិយាយលេងទេ។ យើងត្រូវរៀនគិតថាក្រៅពីទ្រព្យសម្បត្តិហើយ នៅមានរបស់ជាច្រើនទៀតដែលសំខាន់

ជាងនេះ ដូចជា ពេលវេលា គ្រួសារ ស្នេហា ឬសេរីភាពជាដើម។ យើងត្រូវឈប់ផ្តោតទៅលើទ្រព្យដែលយើងមាន ហើយទៅស្វែងរកអ្វីផ្សេងមកជំនួសវិញ។ ដោយសារតែយើងចេះតែគិតពីទ្រព្យពេកទើបមើលលែងឃើញពីតំលៃមនុស្សដូចគ្នា។ យើងគិតថា មនុស្សមិនថ្លៃដូចអ្វីដែលយើងមាន ដែលនេះជាការប្រមាថមួយដ៏ធំបំផុត។ ទោះបីជា ទ្រព្យនោះកើតចេញពីញើសឈាមផ្ទាល់ខ្លួនយើងក៏ដោយក៏មិនចាំបាច់មានអំនួតដែរ។ យើងមិនមែនខំប្រឹងធ្វើការរកស៊ីដើម្បីមានឱកាសមកអួតគេឯណា យើងប្រឹងក៏ដើម្បីតែសេចក្តីសុខគ្រប់ផ្លូវរបស់យើងដែរ។

ហេតុផលទី២ គឺ មានអាយុច្រើន។ មនុស្សមួយចំនួន គិតថាខ្លួនឯងឆ្លងកាត់បទពិសោធន៍ច្រើនជាងគេ ហេតុនេះមិនចេះគោរព និងស្តាប់យោបល់អ្នកណាឡើយ។ បើនៅក្នុងសាលា យើងអាចនឹងជួបគ្រូបែបនេះមិនខាន។ មិនមែនគ្រូទាំងអស់ សុទ្ធតែមានអំនួតអាក្រក់នោះទេ តែមួយចំនួនប៉ុណ្ណោះ។ សច្ចធម៌មួយដែលកម្រនឹងមានគេបង្រៀនគឺ " **បទពិសោធន៍ ជារបស់សម្រាប់ចែករំលែកបន្តជំនាន់ មិនមែនទុកយកមកអឿម្នាក់ឯងនោះទេ** "។ បើយើងដឹងរឿងច្រើន យើងចែកគេចេះដឹងខ្លះក៏មិនខាតដែរ ស្មានតែពេលស្លាប់ទៅ អាចស្ពាយតាមខ្លួនបានអី?

អំនួតដែលកើតពីអាយុច្រើននេះ ងាយស្រួលកែប្រែណាស់ ដោយ

គ្រាន់តែរៀនចែករំលែកអ្វីដែលខ្លួនចេះ ម្ដងបន្តិចៗទៅកាន់អ្នកដទៃប៉ុណ្ណោះ។ យូរៗទៅ នឹងអស់អីត្រូវអួតទៀតហើយ ព្រោះអ្នកដទៃក៏ចេះស្មើគ្នាដែរ។ នៅពេលនោះ ទោះបីជាមិនអួត ក៏អ្នកដទៃមកគោរពដោយឯកឯងដែរ។ ដោយសារសម័យនេះ អ៊ីនធឺណេត មានឥទ្ធិពលខ្លាំងជាងគេ ក្នុងការចែករំលែកចំណេះដឹង ដូច្នេះ យើងអាចចាប់ផ្ដើមបាន។

ហេតុផលទី៣ មានប្រាជ្ញាជាងគេ។ នេះគ្រាន់តែជាហេតុផលបំភាន់ភ្នែកប៉ុណ្ណោះ។ នៅលើលោកនេះ គ្មានអ្នកណាឆ្លាតជាងគេនោះទេ។ មនុស្សម្នាក់អាចឆ្លាតក្នុងរឿងម៉្យាង ហើយល្ងង់ផុតលេខក្នុងរឿងផ្សេងទៀត។ មនុស្សដែលមានអំនួតដោយសារហេតុផលនេះ ជាមនុស្សកុហក។ គេកុហកខ្លួនឯង និងកុហកអ្នកដទៃ។ យើងត្រូវរៀនគិតថា ចំណេះដឹងនៅលើលោកនេះ មានច្រើនរាប់មិនអស់ ទោះបីរៀនមួយជីវិត ក៏នៅតែមានអ្វីរៀនដែរ។ ឬក៏អាចទន្ទេញសុភាសិតមួយឃ្លាថា “**ភ្នំមួយខ្ពស់ នៅមានភ្នំមួយខ្ពស់ជាងទៀត**” ។ តែបើសិនជានៅគិតហេតុផលដដែលទៀត ប្រហែលជាគ្មានអ្វីអាចជួយបានទេ។

នៅពេលដែលខ្ញុំបានផ្ញើរសៀវភៅនេះទៅឱ្យគេជួយកែតម្រូវ អ្នកកែបានបន្ថែមការពន្យល់មួយចំណុចទៀតដែរ។ គាត់សរសេរថា “ការអួតដោយសារតែមានប្រាជ្ញាជាងគេ កើតឡើងដោយសារមានអ្នក

សរសើរច្រើន ហើយក៏បានន័យមួយទៀតថា គេកំពុងតែរស់នៅក្នុងចំណោមមនុស្សល្ងង់ មិនខុសពី កង្កែបក្នុងអណ្តូងទេ ”។ ពាក្យចាស់មួយឃ្លាពោលថា “**កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប**”។

ហេតុផលទី៤ មានសម្រស់ស្អាត។ យើងមានពាក្យសម្រាប់ទទួលមនុស្សប្រភេទនេះថា “**ចរិតស្រីស្អាត ឬប្រុសស្អាត**”។ កើតមកស្អាតជារឿងល្អ មានសំណាងម្យ៉ាង តែបើស្អាតហើយមានអំនួត វាហាក់ដូចជាទៅបំផ្លាញសំណាងខ្លួនឯងចោលអញ្ចឹង។ អ្នកដែលមានមុខមាត់ស្អាត ឬរូបរាងស្អាត យល់ថាខ្លួនគេមានអារ៉ុធពិសេសជាប់ខ្លួនហើយ ហេតុនេះមិនចាំបាច់ខ្វល់ពីក្រសែភ្នែកអ្នកណាទេ តែពួកគេភ្លេចគិតថា ពេលវេលា ជាសត្រូវរបស់ពួកគេ។ ចុះបើថៃ្ងដន្យអី ២ ឆ្នាំក្រោយ អរម៉ូនក្នុងខ្លួនគេផលិតច្រើនជ្រុលទៅ ហើយធ្វើឱ្យមុខរបស់គេជ្រីវជ្រួញកែលែងឡើង តើគេនៅសល់អ្វីទៀត? យើងត្រូវចេះទុកផ្លូវក្រោយសម្រាប់ដើរផង ក្នុងរឿងទំនាក់ទំនងជាមួយអ្នកដទៃនេះ។ ទោះស្អាតប៉ុណ្ណា ក៏ត្រូវការឆ្លាតខ្លះដែរ។

និយាយទៅ **ស្អាត ជារឿងល្អ** ព្រោះខ្ញុំក៏ស្រលាញ់មនុស្សស្អាតដែរ តែដូចជាមិនត្រូវមានអំនួតអីផង ព្រោះនេះបានមកពីធម្មជាតិប៉ុណ្ណោះ ហើយបើអ្នកដែលមិនស្អាតពីធម្មជាតិ ក៏គ្មានអ្វីត្រូវអួតដែរ ព្រោះអ្នកផ្សេងក៏អាចធ្វើបានដូចគ្នា។ គេសរសើរយើងថាស្អាត ហើយ គេទុកយើងជាស្រីស្អាត ឬប្រុសស្អាតហើយ យើងមិនបាច់

ហាត់ខ្លួនឯងទៅធ្វើអ្វើអ្វីទៀតទេ។ មានគេប្រាប់ខ្ញុំថា “ **ការធ្វើចរិតស្រីស្អាត ប្រុសស្អាតនេះ ហត់នឿយខ្លាំងណាស់** ”។

ហេតុផលចុងក្រោយ គឺ ការមានទំនុកចិត្តលើខ្លួនឯងជ្រុលពេក។ មូលហេតុនេះ មិនគួរឱ្យកើតឡើងសោះ។ និស្សិតភាគច្រើន សុទ្ធតែធ្លាប់ចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាល ឬសិក្ខាសាលានានា ដែលគេព្យាយាមបង្កើនទំនុកចិត្តដល់មនុស្ស។ **ប៉ុន្តែទំនុកចិត្ត បើឡើងជ្រុលពេក វានឹងក្លាយជាអំនួតមិនខាន**។

ខ្ញុំបានឃើញរឿងនេះដោយផ្ទាល់ភ្នែក។ កាលនោះខ្ញុំបានចុះឈ្មោះចូលរៀនថ្នាក់ Public Speaking ព្រោះខ្ញុំមិនសូវចេះនិយាយក្នុងចំណោមមនុស្សច្រើន។ មាននិស្សិតម្នាក់បានចុះឈ្មោះរៀនជាមួយខ្ញុំដែរ។ គេមានការខ្លាចពេលនិយាយ ប្រហែលខ្ញុំដែរ។ គេមិនសូវមានមាត់ច្រើនទេក្នុងថ្នាក់ តែខ្ញុំដឹងថាគេខំប្រឹងនិយាយខ្លាំងណាស់។ គេធ្វើតាមការណែនាំរបស់គ្រូទាំងអស់ ល្អជាងខ្ញុំដែលរត់ចោលថ្នាក់ពាក់កណ្តាលទី។ ក្រោយមកទៀត ខ្ញុំក៏ចូលរៀនថ្នាក់ជាមួយនិស្សិតនោះម្តងទៀត ដែលលើកនេះ រៀនមុខវិជ្ជា Fiction Studies។ ខ្ញុំសង្កេតឃើញថា គេហាក់ដូចជាមនុស្សផ្សេងម្នាក់ទៀត។ គេហ៊ាននិយាយ ហ៊ានស្រែកក្នុងថ្នាក់ ហ៊ានឆ្លើយកាត់គ្រូ ហ៊ានធ្វើអ្វីគ្រប់យ៉ាង តែខ្ញុំមានអារម្មណ៍ ទង្វើរ និងចរិតរបស់គេ ដូចជាហួសពីពាក្យថា “**មានទំនុកចិត្ត**”ហើយ។

ដំបូង ខ្ញុំគិតថា ប្រហែលជាខ្ញុំច្រណែននឹងគេ ដែលអាចនិយាយបាន បែបនេះ តែមានអី មិត្តភក្តិខ្ញុំដែលមិនធ្លាប់ស្គាល់គេសោះ ក៏បញ្ចេញ ការមិនពេញចិត្តដូចខ្ញុំដែរ។ កាន់តែអស្ចារ្យនោះ គឺ អ្នកនៅក្នុងក្រុម របស់និស្សិតនោះ តែងតែងាកមុខចេញគ្រប់ពេលដែលម្នាក់នោះ ចាប់ផ្ដើមនិយាយ ហើយធ្វើទឹកមុខធុញទ្រាន់ទៀតផង។ អ្នកណា អាចចូលចិត្តកើត បើនិយាយដូចមានតែឯងក្នុងថ្នាក់បែបនេះនោះ។ ទំនុកចិត្តដែលជារឿងល្អសោះ ត្រូវម្នាក់នេះកែច្នៃទៅជារបស់ដែល គួរឱ្យស្អប់ទៅវិញ។

អ្នកទាំងអស់គ្នាអាចនឹងឆ្ងល់ថា សៀវភៅនេះ និយាយពីជីវិតក្នុង សាកលវិទ្យាល័យ ហេតុអ្វីមកនិយាយរឿងអំនួតទៅវិញ? មកពីខ្ញុំ ចង់បញ្ជាក់ប្រាប់ថា ពេលដែលមនុស្សរៀនដល់សាកលវិទ្យាល័យ យើងអាចនឹងមានអំនួតកាន់តែច្រើនឡើង។ សាកមើលហេតុផល ដែលខ្ញុំលើកឡើងទៅមើល នឹងឃើញហើយថាហេតុផលទាំងនេះ សុទ្ធតែអាចកើតមាននៅក្នុងអំឡុងពេល៤ឆ្នាំនេះទាំងអស់។

ចូលដល់ឆ្នាំទី១ យើងអាចនឹងមានការងារធ្វើ បើសំណាងធ្វើការចំ កន្លែងខ្លាញ់ នោះយើងមានទ្រព្យក្នុងដៃ។ មកដល់ពេលនេះ យើង អាចនឹងមានអាយុ ១៧ ឬ១៨ ឆ្នាំឡើងហើយ យើងនឹងគិតថាយើង ចាស់ល្មមនឹងយល់ពីរឿងផ្សេងៗបានហើយ។ ព្រមគ្នានេះដែរ យើង នឹងគិតថា ប្រាជ្ញារបស់យើងកាន់តែកើនឡើងជាងមុនដោយសារតែ

បានអាន Post លើហ្វេសប៊ុក ឬបានស្ដាប់លោកឫទ្ធី វិភាគពី ៣តិ មានរំលោភនៅប៉ុស្ដិ៍ហង្សមាសរាល់ថ្ងៃ (*ខ្ញុំចូលចិត្តការរបៀបនិយាយរបស់គាត់ណាស់*) ។ ហើយពេលនេះ គឺជាពេលដែលយើងកំពុងតែពេញរូបរាងស្អាតតែម្ដង ដូច្នេះយើងកាន់តែមានទំនុកចិត្តលើខ្លួនឯងម្ដងបន្តិចៗ។ ហេតុផលទាំងអស់ សុទ្ធតែអាចកើតឡើងបានក្នុងពេលរៀននៅសាកលវិទ្យាល័យ។

ការមានអំនួតលើខ្លួនឯង មានផលអាក្រក់ច្រើនណាស់ នៅពេលយើងជានិស្សិត។ នេះមិនមែនបានន័យថា ពេលរៀនចប់ អាចអួតឱ្យអស់ដៃនោះទេ ព្រោះផលអាក្រក់នៅតែកើតមានដូចគ្នា។ ផលអាក្រក់ធំបំផុតនោះ គឺអ្នកដទៃមិនចូលចិត្ត។ បើសិនជាគេមិនចូលចិត្តដោយសារយើងជាមនុស្សថ្នៃប្រឌិតពេក វាជារឿងល្អ តែចំពោះរឿងអំនួតនេះវិញ ចប់ហើយ។ ការដែលអ្នកដទៃមិនចូលចិត្តយើង នឹងធ្វើឱ្យយើងត្រូវរៀនដោយឯកោ ឬមានអ្នកដែលរាប់អានយើងតែសម្បកក្រៅក៏ថាបាន។ វាក៏អាចប៉ះពាល់ដល់ឱកាសការងាររបស់យើងដែរ ព្រោះថា អ្នកដែលគេស្គាល់យើង នឹងមិនហៅយើងទៅធ្វើការជាមួយគេនោះទេ។ គ្រាន់តែរៀន គេមិនចង់រាប់រកផង កុំថាដល់ធ្វើការជាមួយគ្នា។

បើសិនជាយើង មានបំណងចង់ធ្វើអាជីវកម្មខ្លួនឯងទៀតនោះ ការមានអំនួត នឹងបំផ្លាញស្ពានក្នុងសាលាចោលទាំងអស់។ **គ្មានអ្នកណា**

**មកគាំទ្រយើងឡើយ បើគេមិនចូលចិត្តយើង។** យើងត្រូវចាំថា អាជីវកម្ម ត្រូវធ្វើជាមួយមនុស្ស ហេតុនេះទំនាក់ទំនង ជាកូនសោរសំខាន់ជានិច្ច។

ផលអាក្រក់មួយទៀតរបស់ ការមានអំនួតនោះ គឺប៉ះពាល់ដល់អារម្មណ៍អ្នកដទៃ។ គេអាចនឹងស្អប់យើង ឬគុំនឹងយើង។ គេអាចនឹងមកធ្វើអ្វីយើងនៅថ្ងៃក្រោយក៏ថាបាន។ ពេលខ្លះ ខ្ញុំគិតថា ខ្ញុំមើលរឿងភាគច្រើនពេកហើយ ទើបតែងតែខ្លាចអ្នកដទៃមកសងសឹកខ្ញុំនៅថ្ងៃក្រោយបែបនេះ។ តែខ្ញុំសុខចិត្តខ្លាចបែបនេះរហូត ក៏មិនទៅធ្វើឱ្យប៉ះពាល់អ្នកណាដែរ។ អំនួត ប្រៀបដូចជាដំបង២កំណាត់ ពេលគ្រវីគ្រវាត់ឡូយណាស់ តែបើភ្លេចខ្លួន អាចនឹងហួលគ្រប់ពេល។

ពាក្យបុរាណខ្មែរយើងបានពោលថា “ **មនុស្សល្ងង់ លង់ក្នុងអំនួត** ” ដែលនេះស្មើនឹងអត្ថន័យថា **អ្នកដែលមានអំនួត ជាមនុស្សល្ងង់។** យើងអាចទប់ស្កាត់វាបាន ឱ្យតែយើងតាំងចិត្តថាទប់ និងប្រុងប្រយ័ត្នគ្រប់ពេល។ ការមានអំនួត ឬអឿនេះ មិនបានធ្វើឱ្យយើងក្លាយជាមនុស្សអស្ចារ្យនោះទេ ព្រោះមនុស្សអស្ចារ្យមិនចេះអួតពីខ្លួនឯងឡើយ។ ពួកគេទុកឱ្យអ្នកដទៃអួតជំនួសវិញ។ យើងគួរធ្វើអ្វីឱ្យអស់ពីសមត្ថភាពដែលយើងមាន ហើយទុកឱ្យស្នាដៃរបស់យើងអួតដោយខ្លួនវាចុះ។

# ទំព័រចុងក្រោយ

ពួកយើង បានបញ្ចប់សៀវភៅមួយនេះហើយ ដូច្នេះ ខ្ញុំជឿថា យើងទាំងអស់គ្នាក៏បានដឹងពីអ្វីដែលត្រូវធ្វើ នៅសាកលវិទ្យាល័យច្រើនដែរហើយ។ សម្រាប់អ្នកដែលរៀនចប់ អាចជ្រើសរើសយកចំណុចណាដែលគិតថាល្អ ទៅអនុវត្តបន្ត រីឯអ្នកមិនទាន់បានចូលរៀនអាចនឹងត្រៀមខ្លួនទុកឱ្យហើយ ព្រោះនៅពេលដែលមកដល់ភ្លាមៗពេកយើងរកនឹងអ្វីមិនឃើញទេ។ អ្នកដែលកំពុងរៀនវិញ អាចចាប់ផ្ដើមអនុវត្តបាន។

ខ្ញុំមានរឿងមួយចង់សុំបន្តិច។ សូមអ្នកអានទាំងអស់គ្នា ជួយចូលទៅសរសេរ Review នៅលើប្លុករបស់ខ្ញុំផង ដើម្បីឱ្យខ្ញុំបានដឹងពីកម្រិតនៃសៀវភៅមួយនេះ។ Review របស់អ្នកទាំងអស់គ្នា មិនថាតិចឬច្រើនទេ គឺជាកម្លាំងចិត្តដល់សៀវភៅថ្មីរបស់ខ្ញុំនៅពេលក្រោយៗទៀត។

សូមចូលទៅកាន់ Link ខាងក្រោមនេះ ដើម្បីសរសេរ Review ៖

http://wp.me/p5At0U-8E

ខ្ញុំក៏សូមអភ័យទោសផងដែរ បើសិនជាមានកំហុសឆ្គងត្រង់ណាក្នុងសៀវភៅ ឬពាក្យពេចន៍មិនសមរម្យ។ ខ្ញុំសរសេរទៅតាមកម្រិតនៃ

បទពិសោធន៍ក្មេងខ្ចីរបស់ខ្ញុំប៉ុណ្ណោះ ដូច្នេះបើសិនជាអ្នកអាន យល់ដឹងបានច្រើនជាង សូមជួយចូលទៅបន្ថែមនៅក្នុង Link ខាងលើបាន ខ្ញុំនឹងធ្វើការកែតម្រូវ។